# តើប្រទេសកម្ពុជាបានគោរពយន្តការបំពេញបន្ថែមដែរឬទេ? ការអនុវត្តលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិដោយប្រទេសកម្ពុជា

Simon M. MEISENBERG*

simonmmeisenberg@gmail.com

---

*(គ្រោងនឹងបោះពុម្ពផ្សាយនៅក្នុងទិនានុប្បវត្តិអាស៊ីស្តីពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ឆ្នាំ ២០១៣)*

## សេចក្តីសង្ខេប

ក្រោយពីបានឆ្លងកាត់អំពើឃោរឃៅនាពេលកន្លងមក ប្រទេសកម្ពុជាបានចាត់វិធានការវិជ្ជមាន ដើម្បីធ្វើយ៉ាងណាធានាឲ្យមានការចោទប្រកាន់ឲ្យបានត្រឹមត្រូវលើបទឧក្រិដ្ឋអន្តរជាតិនាពេលខាងមុខ អនុលោមតាមលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ (តុលាការព្រហ្មទណ្ឌអន្តរជាតិ) ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ននៅក្នុងឆ្នាំ ២០០២។ ទោះបីជាយ៉ាងនេះក៏ដោយ យន្តការនៃការចាប់ឲ្យមានការទទួលខុសត្រូវ និងយន្តការធ្វើឲ្យរាងចាលដ៏មានប្រសិទ្ធភាពចំពោះបទឧក្រិដ្ឋនាពេលខាងមុខ ចាំបាច់ត្រូវបង្កើតឡើង មិនមែនគ្រាន់ត្រឹមតែចូលរួមជាសមាជិកនៃតុលាការព្រហ្មទណ្ឌអន្តរជាតិតែប៉ុណ្ណោះនោះទេ។ ការយល់ស្របគ្នាជាឯកច្ឆន្ទឃើញមានកាន់តែច្រើនឡើងដោយជំរុញឲ្យរដ្ឋសមាជិក នៃតុលាការព្រហ្មទណ្ឌអន្តរជាតិចែងបញ្ចូលបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមនៅក្នុងច្បាប់ជាតិ ដោយហេតុថាប្រសិនបើពុំមានច្បាប់ចែងទេនោះ វានឹងធ្វើឲ្យប្រទេសនីមួយៗពុំមានលទ្ធភាពចោទប្រកាន់ស្របតាមគោលការណ៍នៃយន្តការបំពេញបន្ថែម។ ប្រទេស កម្ពុជា

---

* ទីប្រឹក្សាផ្នែកច្បាប់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (តាំងពីឆ្នាំ២០១១) អតីតមន្ត្រីច្បាប់ (ឆ្នាំ២០០៥-២០០៩) និងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នៅតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (ឆ្នាំ២០០៩ ដល់ឆ្នាំ២០១១)។ អត្ថបទនេះ បកប្រែដោយលោក ខេង ប៉ូលីដា បច្ចុប្បន្ន ជាមន្ត្រីបកប្រែភាសានៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជាសាស្ត្រាចារ្យភាសាអង់គ្លេសផ្នែកច្បាប់ និងសេដ្ឋកិច្ច នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ អត្ថបទនេះផ្អែកមូលដ្ឋានលើបទបង្ហាញនៅក្នុងឱកាស "ខួបលើកទី១០នៃការចូលជាធរមាននៃលន្តិកទីក្រុងរ៉ូមៈ ដើម្បីប្រយុទ្ធប្រឆាំង នឹងនិទណ្ឌភាព និងការទប់ស្កាត់ឧក្រិដ្ឋកម្មធំៗនៅក្នុងប្រទេសកម្ពុជានាពេលអនាគត" ដែលរៀបចំឡើងដោយសមាគមអាដហុកនៅថ្ងៃទី២ ខែកក្កដា ឆ្នាំ ២០១២ នៅសណ្ឋាគារឡឺរ៉ូយ៉ាល ក្នុងទីក្រុងភ្នំពេញ។ អ្នកនិពន្ធអត្ថបទនេះសូមថ្លែងអំណរគុណដល់ ជា ស៊ីវហ័ង (CHEA Sivhoang) ដែលបានជួយលើបញ្ហាភាសា និងការបកប្រែពីភាសាខ្មែរទៅជាភាសាអង់គ្លេស និង Matteo Crippa, Roger Phillips និង Matthew Cameron ដែលបានផ្តល់យោបល់លើសេចក្តីព្រាងអត្ថបទនេះ។ កំហុសទាំង អស់ផ្សេងទៀតជាការទទួលខុសត្រូវរបស់អ្នកនិពន្ធ ហើយមតិទស្សនៈទាំងអស់ដែលបានលើកឡើងនៅក្នុងនេះពុំមែនជាការយល់ឃើញរបស់អង្គការណាមួយដែលអ្នកនិពន្ធធ្លាប់ធ្វើការ ឬមានទំនាក់ទំនងជាមួយនោះទេ។

បានអនុវត្តតាមនិន្នាការនេះ ហើយបានអនុម័តដាក់បញ្ចូលបទបញ្ញត្តិទាំងនេះនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាថ្មី ឆ្នាំ២០០៩ (ក្រមព្រហ្មទណ្ឌកម្ពុជា)។ ក្រោយពីបានពិនិត្យមើលបទបញ្ញត្តិស្តីពីបទឧក្រិដ្ឋអន្តរជាតិដែលត្រូវបានអនុម័តដាក់បញ្ចូលនៅក្នុងក្រមព្រហ្មទណ្ឌ កម្ពុជានេះរួចមក យើងមើលឃើញយ៉ាងច្បាស់ថា ក្រមបច្ចុប្បន្ននេះចាំបាច់ត្រូវធ្វើវិសោធនកម្ម និងកែទម្រង់ខ្លះដើម្បីឲ្យគោរពឲ្យមានប្រសិទ្ធភាពតាមគោលការណ៍នៃយន្តការបំពេញបន្ថែមដូចមានចែងនៅក្នុងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

ប្រទេសកម្ពុជាធ្លាប់មានស្លាកស្នាមហិង្សានាពេលកន្លងមក។ ទោះបីជាតុលាការបានផ្តោតជាចម្បង លើប្រវត្តិសាស្ត្រចន្លោះពីឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ដែលកងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាពោលគឺ ខ្មែរក្រហមបានធ្វើបដិវត្តន៍ផ្តាច់ការដើម្បីបង្កើតរដ្ឋសង្គមនិយម និងសង្គមឯកពន្ធក៏ដោយ ក៏ប្រទេសនេះបានឆ្លងកាត់បទពិសោធន៍នៃជម្លោះប្រដាប់អាវុធដ៏យូរឆ្នាំចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៩៧[1]។ ទោះបីជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ធ្វើការចោទប្រកាន់លើបទឧក្រិដ្ឋធំៗមួយចំនួនតូចនៅក្នុងអំឡុងសម័យខ្មែរក្រហមក៏ដោយ ក៏ការរំលោភសិទ្ធិមនុស្សទ្រង់ទ្រាយធំៗ និងការបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិនៅតែមាននិទណ្ឌភាពដដែល។ មូលហេតុ គឺ ដោយសារហេតុផលមួយចំនួន ទាំងផ្នែកនយោបាយ និងច្បាប់[2]។ ឧបសគ្គផ្លូវច្បាប់មួយទៀតធ្វើឲ្យមាននិទណ្ឌភាពដែរនោះ គឺដោយសារហេតុផលថា បទឧក្រិដ្ឋអន្តរជាតិ ដូចជាបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋសង្គ្រាម និងបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ (ចាប់ពីពេលនេះទៅហៅថា បទឧក្រិដ្ឋអន្តរជាតិ) ពុំត្រូវបានចែងបញ្ចូលជាបទល្មើសនៅក្នុងច្បាប់ព្រហ្មទណ្ឌជាតិ នៅពេលដែលឧក្រិដ្ឋកម្មទាំងនេះបានប្រព្រឹត្តឡើង។ ក្រមព្រហ្មទណ្ឌកម្ពុជា[3]កំណត់នូវ

---

[1] Lucy KELLER, UNTAC in Cambodia – from Occupation, Civil War and Genocide to Peace, *Max Planck Yearbook of United Nations Law 9 (2005)*, 127-178; A. Rapp/ C. Philipp, Conflicts Cambodia/Kampuchea, in Rüdiger WOLFRUM, *United Nations: Law, Policies and Practice, Volume I (1995)*, 200 et seq.

[2] "កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ដែលចូលជាធរមាននៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ សន្និសញ្ញានៃអង្គការសហប្រជាជាតិ លេខ៤១៧២៣ នៅលើគេហទំព័រ http://www.eccc.gov.kh/sites/default/files/legal-documents/Agreement_between_UN_and_RGC.pdf (ចូលអានចុងក្រោយនាថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ២០១៣)។ សូមមើលផងដែរ "ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ" ដែលត្រូវបានអនុម័តដោយរដ្ឋសភាជាតិនាថ្ងៃទី២ ខែមករា ឆ្នាំ២០០១ និងព្រឹទ្ធសភានៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០១ ហើយត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/១០០៤/០០៦ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១។

[3] ជឹង ប៊ុនឡេង ក្រមព្រហ្មទណ្ឌ សំណៅបកប្រែជាភាសាខ្មែរ-អង់គ្លេស (ទីក្រុងភ្នំពេញ ខែ ឧសភា ឆ្នាំ ២០១១)។ ក្រមព្រហ្មទណ្ឌកម្ពុជាត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩។ សេចក្តីយោង ជាភាសាអង់គ្លេសទៅរកក្រមព្រហ្មទណ្ឌកម្ពុជាត្រូវបានដកស្រង់ចេញមកពីសំណៅបកប្រែក្រៅផ្លូវការដោយ ជឹង ប៊ុនឡេង។

គោលការណ៍*គ្មានបទល្មើស ប្រសិនបើគ្មានច្បាប់ចែង* ឬគោលការណ៍នីត្យានុកូលភាព[4]។ អ.វ.ត.ក ត្រូវបានបង្កើតឡើងក្នុងឋានៈជាស្ថាប័នតុលាការ*ពិសេស*មួយ ដើម្បីជំនុំជម្រះលើបទឧក្រិដ្ឋដែលកើតឡើងជាង៣០ឆ្នាំរួចមកហើយ និងដើម្បីដោះស្រាយបញ្ហាគតិយុត្តិកើតឡើងក្រោយអង្គហេតុផ្អែកតាមច្បាប់ជាតិ ឬវិធានច្បាប់ទំនៀមទម្លាប់ដែលចែងអំពីនៃការទទួលខុសត្រូវជាលក្ខណៈបុគ្គលលើបទឧក្រិដ្ឋអន្តរជាតិមួយចំនួន[5]។

ចាប់តាំងពីពេលអនុម័តលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិរួចមក (លក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ ឬលក្ខន្តិកទីក្រុងរ៉ូម)[6] ប្រទេសកាន់តែច្រើនឡើងៗធានាថា ប្រព័ន្ធច្បាប់ក្នុងស្រុករបស់ពួកគេបានដាក់បញ្ចូលបទឧក្រិដ្ឋដែលមានចែងនៅក្នុងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយស្ថិតនៅក្រោមយុត្តាធិការនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ថាជាបទល្មើសព្រហ្មទណ្ឌ[7]។ និន្នាការរបស់រដ្ឋជាច្រើនដែលងាកទៅរកការដាក់ឲ្យមានការទទួលខុសត្រូវបែបនេះ គឺកើតចេញពីការយល់ឃើញថា និទ្ទណ្ឌភាពចំពោះអំពើឃោរឃៅដូចធ្លាប់បានកើតមាននៅក្នុងសតវត្សរ៍ទី២០ ពុំអាចទទួលនូវការអត់ឱនបានតទៀតទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ មានហេតុផលច្បាប់មួយដែរ។ តុលាការព្រហ្មទណ្ឌអន្តរជាតិបានយកគោលការណ៍នៃយន្តការបំពេញបន្ថែមធ្វើជាមូលដ្ឋាន និងផ្តល់ឧត្តមានុភាពដល់ប្រព័ន្ធតុលាការជាតិក្នុងការចោទប្រកាន់បទឧក្រិដ្ឋនានានៅក្រោមយុត្តាធិការរបស់ខ្លួន។ នៅក្នុងករណីដែលរដ្ឋគ្មានឆន្ទៈ ឬ មិនអាចចោទប្រកាន់បាន ទើបតុលាការព្រហ្មទណ្ឌអន្តរជាតិអាចអនុវត្តយុត្តាធិការរបស់ខ្លួនដើម្បីចោទប្រកាន់បុគ្គលណាមួយបាន។ រដ្ឋសមាជិកបានយល់ស្របគ្នាជាឯកច្ឆន្ទកាន់តែច្រើនឡើងថា ខ្លួនគួរយកបទឧក្រិដ្ឋនៅក្នុងលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ មកចែងដាក់បញ្ចូលនៅក្នុងច្បាប់ក្នុងស្រុករបស់ខ្លួន ដោយសារថា ប្រសិនបើពុំមានច្បាប់ចែងទេនោះ វាអាចបណ្តាលឲ្យមាននិទ្ទណ្ឌភាព និងនាំដល់ការចាត់ទុកថា រដ្ឋមិនមានលទ្ធភាពចោទប្រកាន់បទឧក្រិដ្ឋដែលមានចែងនៅក្នុងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ។

---

[4] មាត្រា ៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា (គោលការណ៍នីត្យានុកូលភាព) ចែងថា៖ "មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន"។

[5] អ.វ.ត.ក *កាំង ហ្គេកអ៊ាវ* សំណុំរឿង ០០១/១៨-០៧-២០០៧/អវតក/អជសដ សាលក្រម ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នា ២០១០ កថាខណ្ឌ ២៨-៣៤។

[6] ឯកសារ អ.ស.ប លេខ A/CONF 183/9 លក្ខន្តិកទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ បើកឲ្យចុះហត្ថលេខានៅថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ១៩៩៨ [ឆ្នាំ២០០២] ATS 15 (ចូលជាធរមាននៅថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០២) (ចាប់ពីពេលនេះទៅហៅថា លក្ខ ន្តិកទីក្រុងរ៉ូម ឬលក្ខន្តិកនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ) ដែលអាចពិនិត្យមើលបាននៅលើគេហទំព័រ http://untreaty.un.org/cod/icc/statute/romefra.htm (ចូលអានចុងក្រោយនាថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣)។

[7] សូមមើល ប្រទេសអាល្លឺម៉ង់ ច្បាប់អនុម័ត ក្រមស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងច្បាប់អន្តរជាតិ ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០០២។ ប្រទេសអូស្ត្រាលី ច្បាប់ ឆ្នាំ២០០២ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ លេខ 41 ឆ្នាំ២០០២ និងច្បាប់ (វិសោធនកម្មនាពេលក្រោយៗ) ឆ្នាំ ២០០២ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ប្រទេសហូឡង់ដ៍ ច្បាប់ស្តីពីឧក្រិដ្ឋកម្មអន្តរជាតិ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០០២។ សាធារណរដ្ឋអាហ្វ្រិកខាងត្បូង ការអនុវត្ត លក្ខន្តិកទីក្រុងរ៉ូមនៃច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិលេខ27 ឆ្នាំ២០០២។ ចក្រភពអង់គ្លេស ច្បាប់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិឆ្នាំ២០០១។

ប្រទេសកម្ពុជាបានដើរតាមនិន្នាការនេះ ហើយក្រោយពីផ្តល់សច្ចាប័នលើលក្ខន្តិកទីក្រុងរ៉ូម នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០២ រួចមក[8] ប្រទេសកម្ពុជាបានចែងបញ្ចូលបទបញ្ញត្តិទាំងនោះទៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩។ នេះជាការវិវឌ្ឍថ្មីមួយដែលសមនឹងទទួលបានការស្វាគមន៍ និងអាចធ្វើឲ្យប្រទេសកម្ពុជាអាចរក្សាយុត្តាធិការផ្នែកព្រហ្មទណ្ឌលើបទឧក្រិដ្ឋអន្តរជាតិទាំងនោះបាន។ ទោះបីជាយ៉ាងនេះក្តី នៅពេលពិនិត្យឲ្យបានស៊ីជម្រៅលើបទបញ្ញត្តិស្តីពីបទឧក្រិដ្ឋអន្តរជាតិដែល ត្រូវបានយកមកចែងដាក់បញ្ចូលទៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា វាធ្វើឲ្យមានការព្រួយបារម្ភ ហើយ ត្រូវប្រយ័ត្នប្រយែង។ អត្ថបទនេះនឹងពិនិត្យមើលបទបញ្ញត្តិទាំងនេះ ហើយនឹងពិភាក្សាអំពីបញ្ហានៃយន្តការបំពេញបន្ថែម។ គោលការណ៍នៃយន្តការបំពេញបន្ថែមនឹងលើកឡើងដោយសង្ខេបនៅក្នុងផ្នែកទី I។ ផ្នែកទី II នឹងបង្ហាញការវិភាគលម្អិតលើបទបញ្ញត្តិ និងនិយមន័យនៃបទឧក្រិដ្ឋអន្តរជាតិដែលត្រូវបានចែងបញ្ចូលទៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា។ បញ្ហាចោទពាក់ព័ន្ធនឹងទម្រង់នៃការទទួលខុសត្រូវ អភ័យឯកសិទ្ធិ និងការរារាំងលើការចោទប្រកាន់នឹងលើកឡើងនៅក្នុងផ្នែកទី III ដល់ ផ្នែកទី IV។ បញ្ហាគតិយុត្តិចម្បង ថាតើបទបញ្ញត្តិព្រហ្មទណ្ឌទាំងនេះបានគោរពតាមនិយមន័យនៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិដែរឬយ៉ាងណា ហើយថាតើវាប្រកាន់ខ្ជាប់ត្រឹមត្រូវទៅតាមលក្ខខណ្ឌនៃយន្តការបំពេញបន្ថែមនៅក្នុងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិដែរឬទេ នឹងយកមកពិភាក្សានៅក្នុងផ្នែកទី V។

## I. គោលការណ៍នៃយន្តការបំពេញបន្ថែមនៅក្នុងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ

លក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិបានផ្អែកលើគោលការណ៍នៃយន្តការបំពេញបន្ថែម ពុំមែនគោលការណ៍ឧត្តមានុភាពស្តីពីយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិទេ។ គោលការណ៍នេះបានគូសបញ្ជាក់នៅក្នុងបុព្វកថា និងមាត្រា១ នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិដែលបានចែងយ៉ាងច្បាស់ថា លក្ខន្តិកនេះត្រូវ "បំពេញបន្ថែមលើយុត្តាធិការព្រហ្មទណ្ឌជាតិ" [9]។ ការចែងដូច្នេះ គឺក្នុងហេតុផលដើម្បីរក្សាអធិបតេយ្យរបស់រដ្ឋនីមួយៗ ក៏ប៉ុន្តែក្នុងពេលជាមួយគ្នានេះ ក៏ដើម្បីធ្វើឲ្យរដ្ឋសមាជិកធ្វើការចោទប្រកាន់បទឧក្រិដ្ឋអន្តរជាតិ ដោយអនុវត្តនិន្នវកាតព្វកិច្ចនៃយុត្តាធិការព្រហ្មទណ្ឌរបស់ខ្លួនលើបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម[10]។ ដោយសារគោលការណ៍នៃយន្តការបំពេញបន្ថែមនេះហើយ

---

[8] សូមមើលគេហទំព័រ http://www.icc-cpi.int/en_menus/asp/states%20parties/asian%20states/Pages/cambodia.aspx (បើកអានចុងក្រោយនាថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣)។

[9] បុព្វកថានៃលក្ខន្តិករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ មាត្រា១ នៃលក្ខន្តិករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[10] Markus BENZIG, The Complementarity Regime of the International Criminal Court: International Criminal Justice between State Sovereignty and the Fight against Impunity, *Max Planck Yearbook of United Nations Law 7 (2003)*, 591-632, at 595 *et seq*; Jann K. KLEFFNER, The Impact of Complementarity on National Implementation of Substantive International Criminal Law, *Journal of International Criminal Justice 1 (2003)*, 86-113, at 87.

ទើបតុលាការក្នុងស្រុកមានឧត្តមានុភាពលើតុលាការព្រហ្មទណ្ឌអន្តរជាតិ[11]។ មាត្រា១៧(១) នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិកំណត់អំពីស្ថានភាពដែលតុលាការព្រហ្មទណ្ឌអន្តរជាតិ មិនអាចអនុវត្តយុត្តាធិការរបស់ខ្លួនបាន៖ (១) រឿងក្តីដែលកំពុងធ្វើការស៊ើបអង្កេត និងចោទប្រកាន់ ដោយរដ្ឋដែលមានយុត្តាធិការលើរឿងក្តីនោះ។ (២) រឿងក្តីដែលត្រូវបានស៊ើបអង្កេតរួចរាល់ដោយ រដ្ឋដែលមានយុត្តាធិការ ហើយរដ្ឋនេះបានសម្រេចមិនចោទប្រកាន់បុគ្គលពាក់ព័ន្ធ(៣) បុគ្គល ពាក់ព័ន្ធត្រូវបានជំនុំជម្រះរួចហើយចំពោះទង្វើដែលជាកម្មវត្ថុនៃបណ្តឹង។ និង(៤) រឿងក្តីពុំមាន ភាពធ្ងន់ធ្ងរគ្រប់គ្រាន់ដើម្បីផ្តល់យុត្តិកម្មឲ្យតុលាការចាត់វិធានការបន្ថែម[12] ។ ដូច្នេះ មាត្រា៧(១) នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិចែងបំភ្លឺថា រឿងក្តីនៅចំពោះមុខតុលាការព្រហ្មទណ្ឌ អន្តរជាតិអាចទទួលយកមកជំនុំជម្រះបាន ដរាបណារដ្ឋសមាជិកមិនមានលទ្ធភាព ឬ មិនមានឆន្ទៈ ក្នុងការស៊ើបអង្កេត ឬចោទប្រកាន់រឿងក្តីនោះតែប៉ុណ្ណោះ[13]។

លក្ខខណ្ឌស្តីពីការមិនមានលទ្ធភាពដែលមានចែងនៅក្នុងមាត្រា១៧(៣) នៃលក្ខន្តិក តុលាការព្រហ្មទណ្ឌអន្តរជាតិ បានតម្រូវឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវតែពិចារណាថា តើ "ដោយសារការបរាជ័យធំធេង ឬដោយសារប្រព័ន្ធតុលាការជាតិមិនដំណើរការ ទើបរដ្ឋមិនមាន លទ្ធភាពឃុំខ្លួនជនជាប់ចោទ ឬប្រមូលយកភ័ស្តុតាង និងសក្ខីកម្មចាំបាច់ ឬមកពីហេតុផលផ្សេង ពីនេះ ទើបរដ្ឋមិនមានលទ្ធភាពដំណើរការនីតិវិធីរបស់ខ្លួនបាន"[14]។ ការយល់ស្របជាឯកច្ឆន្ទច្រើន លើសលប់បានលើកឡើងថា ឃ្លា"មកពីហេតុផលផ្សេងពីនេះ ទើបរដ្ឋមិនមានលទ្ធភាពដំណើរការ នីតិវិធីរបស់ខ្លួនបាន" គ្របដណ្តប់រួមទាំងករណីនត្ថិភាព ឬភាពមិនគ្រប់គ្រាន់នៃច្បាប់សារធាតុ ហេតុនេះ ហើយ នៅក្នុងកាលៈទេសៈបែបនេះ រឿងក្តីនេះអាចទទួលយកមកជំនុំជម្រះនៅចំពោះមុខ តុលាការព្រហ្មទណ្ឌអន្តរជាតិបាន[15]។ ដូច្នេះ រដ្ឋសមាជិកមានបន្ទុកក្នុងការធ្វើសុខដុមកម្ម ឬចែង បញ្ចូលបទឧក្រិដ្ឋអន្តរជាតិទៅក្នុងច្បាប់ក្នុងស្រុកដើម្បីឲ្យមានឧត្តមានុភាពផ្នែកយុត្តាធិការលើបទ

---

[11] Markus BENZIG, លេខយោងជើងទំព័រ១០ *ដូចខាងលើ*, at 630; Julio Bacio TERRACINO, National Implementation of ICC Crimes: Impact on National Jurisdictions and the ICC, *Journal of International Criminal Justice 5* (2007), 421-440, at 421.

[12] Lijun YANG, On the Principle of Complementarity in the Rome Statute of the International Criminal Court, *Chinese Journal of International Law 4 (2005)*, 121-132, at 122.

[13] មាត្រា ១៧(៣) នៃលក្ខន្តិករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[14] ចំពោះការពិភាក្សាលម្អិតជាងនេះអំពីធាតុផ្សំនៃ "ការពុំមានលទ្ធភាព" សូមមើល Markus BENZIG, លេខយោងជើងទំព័រ ១០ *ដូចខាងលើ* ត្រង់ទំព័រ ៦១៣ និងទំព័របន្តបន្ទាប់ទៀត។

[15] Luigi CONDORELLI, La Cour pénale internationale: un pas géant (pourvu qu'il soit accompli ...), *Revue génerale de droit internationale public 103 (1999)*, 7-21; Katherine L. DOHERTY and Timothy L.H. MCCORMACK, 'Complementarity' as a Catalyst for Comprehensive Domestic Penal Legislation, *U.C. Davis Journal of International Law and Policy 5 (1999)*, 147-180, at 152; Flavia LATTANZI, The International Criminal Court and National Jurisdictions, in Mario POLITI and Giuseppe NESI (eds.), *The Rome Statute of the International Criminal Court – A Challenge to Impunity (Aldershot: Ashgate, 2001)*, 177-223, at 181; Jann K. KLEFFNER, លេខយោងជើងទំព័រ ១០ *ដូចខាងលើ* at 89.

ឧក្រិដ្ឋទាំងនេះ[16]។ ប្រសិនបើក្របខណ្ឌគតិយុត្តិក្នុងស្រុកពុំធានាបាននូវការចោទប្រកាន់ពិតប្រាកដលើបទឧក្រិដ្ឋទាំងនេះ ដោយអនុលោមតាមមាត្រា១៧(៣) នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិនោះទេ នៅពេលនោះតុលាការព្រហ្មទណ្ឌអន្តរជាតិនឹងត្រូវកំណត់ថា ប្រព័ន្ធតុលាការក្នុងស្រុកពុំមានលទ្ធភាពដំណើរការចោទប្រកាន់[17]។

## II. ការដាក់បញ្ចូលបទឧក្រិដ្ឋអន្តរជាតិទៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា

ដោយសារការយល់ឃើញដូចខាងលើនេះហើយ ទើបរដ្ឋសមាជិកនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានចែងបញ្ចូលបទបញ្ញត្តិស្តីពីបទឧក្រិដ្ឋអន្តរជាតិនៅក្នុងក្របខណ្ឌច្បាប់ព្រហ្មទណ្ឌក្នុងស្រុករបស់ខ្លួន[18]។ ព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម នៅក្នុងក្រមព្រហ្មទណ្ឌរបស់ខ្លួនដែលត្រូវបានប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៨ (ក្រមនីតិវិធីព្រហ្មទណ្ឌ) ពុំមានចែងអំពីនីតិវិធីជាក់លាក់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋអន្តរជាតិទាំងនេះឡើយ លើកលែងតែបទបញ្ញត្តិជាក់លាក់មួយចំនួនពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន[19] និងការលុបចោលនូវអាជ្ញាយុកាលតែប៉ុណ្ណោះ[20]។ ផ្នែកនេះនឹងវាយតម្លៃថាតើបទបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាចែងត្រឹមត្រូវអំពីបទឧក្រិដ្ឋទាំងនេះដែរឬទេ ហើយថាតើក្រមនេះធានាបាននូវឧត្តមានុភាពលើបទឧក្រិដ្ឋអន្តរជាតិដែរឬក៏អត់។ អ្នកតាក់តែងច្បាប់របស់កម្ពុជាបានជ្រើសរើសយកបទបញ្ញត្តិនៅក្នុងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ មកចែងដាក់បញ្ចូលនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាដែលទើបអនុម័តនាពេលថ្មីៗ ដោយពុំបានចែងជាក្រមដាច់ដោយឡែកមួយនោះឡើយ។ ចំពោះបញ្ហាចោទផ្នែកយុត្តាធិការលើបទឧក្រិដ្ឋអន្តរជាតិវិញ តុលាការកម្ពុជានឹងមានសមត្ថកិច្ច ប្រសិនបើបទឧក្រិដ្ឋបែបនេះត្រូវបានប្រព្រឹត្តឡើងនៅលើទឹកដីនៃព្រះរាជណាចក្រកម្ពុជា[21]។ ក្រមព្រហ្មទណ្ឌកម្ពុជាពុំផ្តល់យុត្តាធិការសកលលើបទឧក្រិដ្ឋអន្តរជាតិឡើយ ប៉ុន្តែតម្រូវឲ្យមានចំណងទាក់ទងជាមួយនឹងទឹកដីកម្ពុជា[22] ចារីជាពលរដ្ឋកម្ពុជា[23] ឬ ជនរងគ្រោះជាពលរដ្ឋកម្ពុជា[24]។

---

[16] Jann K. KLEFFNER, លេខយោងជើងទំព័រ ១០ *ដូចខាងលើ* ត្រង់ទំព័រ ៨៨។ Markus BENZIG, លេខយោងជើងទំព័រ ១០ *ដូចខាងលើ* ត្រង់ទំព័រ ៦១៥។

[17] Markus BENZIG, លេខយោងជើងទំព័រ ១០ *ដូចខាងលើ* ត្រង់ទំព័រ ៦១៥។

[18] លេខយោងជើងទំព័រ ៧ *ដូចខាងលើ*។

[19] សូមមើល មាត្រា ២១០ និង ៦០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[20] សូមមើល មាត្រា ៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[21] មាត្រា ១២ (គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា) ចែងថា៖ "ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវ អនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ដែនដីនៃ ព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងលំហអាកាស និងសមុទ្រ ដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា"។

[22] មាត្រា ១៣ (ទីកន្លែងប្រព្រឹត្តបទល្មើស) ចែងថា៖ "បទល្មើសត្រូវបានចាត់ថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅពេលដែលអំពើណាមួយនៃបទល្មើសនោះ បានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា"។

មានតែករណីលើកលែងចំនួនបីតែប៉ុណ្ណោះដែលនិយមន័យនៅក្នុងមាត្រា ៦ នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ និងនិយមន័យនៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិនៅក្នុងមាត្រា ៧ នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានយកពាក្យពេចន៍ដើមមកចែងបញ្ចូលនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា។ ក៏ប៉ុន្តែ បទឧក្រិដ្ឋសង្គ្រាមដែលមានចែងនៅក្នុងមាត្រា ៨ នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ ពុំត្រូវបានចែងបញ្ចូលទៅតាមពាក្យពេចន៍ដើមនោះទេ។ ភាពខុសគ្នានៅក្នុងបទឧក្រិដ្ឋ ប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិនឹងត្រូវយកមកបង្ហាញដោយសង្ខេប មុនពេលធ្វើការវិភាគលម្អិតលើបទឧក្រិដ្ឋសង្គ្រាម ជាពិសេស ពាក់ព័ន្ធនឹងបញ្ហាចោទនៃយន្តការបំពេញបន្ថែម។

### *ក. បទឧក្រិដ្ឋប្រល័យពូជសាសន៍*

ប្រទេសកម្ពុជាបានចូលជាភាគីនៃអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៥៩ ហើយបទឧក្រិដ្ឋប្រល័យពូជសាសន៍ត្រូវបានកំណត់និយមន័យនៅក្នុងមាត្រា ១៨៣នៃក្រមព្រហ្មទណ្ឌកម្ពុជា[25]។ និយមន័យនៃបទឧក្រិដ្ឋប្រល័យពូជសាសន៍ភាគច្រើនស្រដៀងគ្នានឹងនិយមន័យនៅក្នុងអនុសញ្ញាស្តីពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ និងមាត្រា៦ នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ទោះបីជាយ៉ាងនេះក៏ដោយ យើងឃើញមានភាពខុសគ្នាតិចតួចដែលត្រូវយកមកពិភាក្សា។ ពាក់ព័ន្ធនឹងនិយមន័យអំពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទបញ្ញត្តិកម្ពុជាពាក់ព័ន្ធនឹងការដាក់វិធានការសំដៅរារាំងកំណើតទារកដែលជាអំពើនៃបទឧក្រិដ្ឋប្រល័យពូជសាសន៍ មានលក្ខណៈខុសគ្នាពីមាត្រា៦(ឃ) នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ។ លក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិចែងថា "ការដាក់វិធានការសំដៅរារាំងកំណើតទារកនៅក្នុងក្រុម" កាលបើអំពើនេះត្រូវបានប្រព្រឹត្តក្នុងគោលបំណងបំផ្លាញទាំងមូល ឬមួយផ្នែកនៃក្រុមជាតិ ជាតិពិន្ទុ ពូជសាសន៍ ឬសាសនា គឺជាបទឧក្រិដ្ឋប្រល័យពូជសាសន៍។ និយមន័យអនុលោមតាមមាត្រា

---

[23] មាត្រា ១៩ នៃក្រមព្រហ្មទណ្ឌកម្ពុជា។ បទប ញ្ញត្តិស្តីពីឧក្រិដ្ឋកម្មអន្តរជាតិគឺជាបទឧក្រិដ្ឋកម្មក្រោមក្រមព្រហ្មទណ្ឌកម្ពុជា ដោយហេតុថាឧក្រិដ្ឋកម្មទាំងនេះត្រូវផ្តន្ទាទោសលើសពីប្រាំឆ្នាំ សូមមើល ការបែងចែកនេះនៅក្នុងមាត្រា ៤៦ និងមាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា។

[24] មាត្រា ២០ (ជនរងគ្រោះជាជនជាតិខ្មែរ) ចែងថា៖ "ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពលរដ្ឋខ្មែរ ឬ ដោយ ជនបរទេសទៅលើជនរងគ្រោះដែលមានសញ្ជាតិខ្មែរនៅក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត"។

[25] មាត្រា ១៨៣ (បទឧក្រិដ្ឋប្រល័យពូជសាសន៍) ចែងថា៖ "បទឧក្រិដ្ឋប្រល័យពូជសាសន៍ គឺជាអំពើ ណាមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនេះត្រូវបានប្រព្រឹត្តក្នុងគោលបំណងបំផ្លាញទាំងមូល ឬ មួយផ្នែកនៃក្រុមជាតិជាតិពិន្ទុ ពូជសាសន៍ ឬ សាសនា៖

1. ឃាតកម្មលើសមាជិកនៃក្រុម។
2. ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើបូរណភាពខាងរូបកាយ ឬ សតិបញ្ញារបស់សមាជិកនៃក្រុម។
3. ការដាក់ឲ្យសមាជិកនៃក្រុមរស់នៅក្នុងលក្ខខណ្ឌ ដែលនាំឲ្យវិនាសអន្តរាយទាំងស្រុង ឬ មួយផ្នែកនៃក្រុម។
4. វិធានការដោយបង្ខំ ឬ មធ្យោបាយដោយមិនបង្ខំ សំដៅរារាំងកំណើតទារកនៅក្នុងក្រុម។
5. ជម្លៀសដោយបង្ខំនូវកុមារពីក្រុមមួយទៅក្រុមមួយផ្សេងទៀត។

១៨៣(៨)នៃក្រមព្រហ្មទណ្ឌកម្ពុជាមានចំណុចខុសគ្នា ដោយសារក្រមព្រហ្មទណ្ឌកម្ពុជាតម្រូវឲ្យមានការ "ដាក់វិធានការ*ដោយបង្ខំ* ឬមធ្យោបាយ*ដោយមិនបង្ខំ*សំដៅរារាំងកំណើតទារកនៅក្នុងក្រុម"[26]។ ការបន្ថែមពាក្យ "ដោយបង្ខំ" ហាក់ដូចជាពាក្យច្រំដែល ដោយសារថាពាក្យ "ដាក់" បានបង្កប់ន័យថាជាវិធានការដោយបង្ខំរួចទៅហើយ។ ដូច្នេះ ការបន្ថែមពាក្យនេះពុំទំនងជាធ្វើឲ្យប្រែប្រួលធំធេងលើនិយមន័យនៃអំពើដូចបានគូសបញ្ជាក់នេះឡើយ។ ក៏ប៉ុន្តែ ការបន្ថែមពាក្យ "មធ្យោបាយដោយមិនបង្ខំ" ទំនងជាពង្រីកវិសាលភាពនៃអំពើមួយនៃបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឲ្យហួសពីការបកស្រាយដើម។ ក្រៅពីធ្វើឲ្យពាក្យការដាក់មធ្យោបាយដោយមិនបង្ខំមានន័យផ្ទុយគ្នា វាធ្វើឲ្យយើងពិបាកក្នុងការកំណត់ស៊ីនណារីយ៉ូណាដែលថាជាមធ្យោបាយដោយមិនបង្ខំត្រូវបានដាក់ឡើងដើម្បីសំដៅរារាំងកំណើតទារក[27]។ ផ្ទុយមកវិញ វិធានការណាមួយដែលបានដាក់ឡើងត្រូវធ្វើឡើងរួមជាមួយនឹងវិធានការដោយបង្ខំ[28]។

ឧទាហរណ៍ ប្រសិនបើរដ្ឋាភិបាលមួយស្នើឲ្យមានកម្មវិធីរៀបចំផែនការគ្រួសារនៅក្នុងសហគមន៍ជាតិពិន្ទុជាក់លាក់ណាមួយក្នុងគោលបំណងប្រល័យពូជសាសន៍ ហើយរដ្ឋាភិបាលនេះសង្ឃឹមថានឹងមានកិច្ចសហប្រតិបត្តិការណ៍ដោយស្ម័គ្រចិត្តនៅក្នុងចំណោមសមាជិកសហគមន៍ ដូច្នេះ យើងពិបាកក្នុងការបំពេញលក្ខខណ្ឌតម្រូវនៃអំពើនេះណាស់ប្រសិនបើបុគ្គលទាំងឡាយទទួលបានការជូនដំណឹង និងដឹងអំពីផលវិបាកនៃកម្មវិធីរៀបចំផែនការគ្រួសារ។ សរុបមក វាបង្ហាញឲ្យឃើញថា ការកែប្រែលើបទបញ្ញត្តិនេះនឹងពុំមានអានុភាពលើការវាយតម្លៃចំពោះគោលការណ៍នៃយន្តការបំពេញបន្ថែមនោះទេ ដោយសារនិយមន័យនៃបទឧក្រិដ្ឋប្រល័យពូជសាសន៍នៅក្នុងមាត្រា១៨៣(៨) នៃក្រមព្រហ្មទណ្ឌកម្ពុជាមានលក្ខណៈទូលាយជាងមាត្រា៦(៨) នៅក្នុងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ។

---

[26] មាត្រា៦(ឃ) នៃលក្ខន្តិករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិចែងថា៖ "សម្រាប់គោលបំណងនៃលក្ខន្តិកនេះ បទឧក្រិដ្ឋប្រល័យពូជសាសន៍" មានន័យថាជាអំពើណាមួយក្នុងចំណោមអំពើខាងក្រោមដែលបានប្រព្រឹត្តឡើងដោយមានចេតនាបំផ្លាញទាំងស្រុង ឬ មួយផ្នែកនៃក្រុមជាតិ ជាតិពិន្ទុ ពូជសាសន៍ ឬ សាសនា៖

[...]

(ឃ) ការដាក់វិធានការក្នុងចេតនាទប់ស្កាត់ការបង្កកំណើតនៅក្នុងក្រុម"។

[27] តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា ICTR បានចាត់ទុកការគ្រប់គ្រងលើការបង្កកំណើតដោយបង្ខំជាអំពើពាក់ព័ន្ធមួយនៅក្រោមបទបញ្ញត្តិនេះ សូម មើល រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង AKAYESU*, សាលក្រម, ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥០៧។

[28] Florian JESSBERGER, The Definition and the Elements of the Crime of Genocide, in Paola GAETA, *The UN Genocide Convention – A Commentary* (Oxford: Oxford University Press, 2009), 87-111, at 102.

## *ខ. បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ*

ពាក្យពេចន៍ខុសគ្នាឃើញមាននៅក្នុងបទបញ្ញត្តិនៃបទល្មើសចំនួនពីរនៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិនៅក្នុងមាត្រា១៨៨នៃក្រមព្រហ្មទណ្ឌកម្ពុជា[29]។ និយមន័យនៃអំពើធ្វើទុក្ខបុកម្នេញក្នុងមាត្រា៧ នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិបានចែងថា "មូលដ្ឋានផ្សេងទៀតដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិថាជាមូលដ្ឋានខុសច្បាប់នៅក្នុងច្បាប់អន្តរជាតិ ដែលជាប់ពាក់ព័ន្ធនឹងអំពើណាមួយនៅក្នុងកថាខណ្ឌនេះ ឬដែលជាបទល្មើសណាមួយនៅក្នុងយុត្តាធិការរបស់តុលាការ" អាចត្រូវបានចាត់ទុកថាមានលក្ខណៈជាការធ្វើទុក្ខបុកម្នេញ។ ប្រសិនបើប្រៀបធៀបជាមួយនឹងនិយមន័យផ្សេងទៀត បទបញ្ញត្តិចុងក្រោយនេះបានពន្លាតនិយមន័យនៃអំពើធ្វើទុក្ខបុកម្នេញ នៅពេលអំពើទាំងឡាយណាត្រូវបានប្រព្រឹត្តឡើងក្នុងចេតនានយោបាយ ពូជសាសន៍ ជាតិសាសន៍ ជាតិពន្ធ វប្បធម៌ សាសនា ឬ យេនឌ័រ[30]។ បទបញ្ញត្តិនេះពុំឃើញមានចែងនៅក្នុងមាត្រា១៨៨(៨) នៃក្រមព្រហ្មទណ្ឌកម្ពុជានោះទេ។ ដូច្នេះ អំពើធ្វើទុក្ខបុកម្នេញត្រូវបានកំណត់និយមន័យយ៉ាងចង្អៀត ប្រសិនបើយកទៅប្រៀបធៀបជាមួយនឹងនិយមន័យនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ចំណុចទីពីរ លក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិនៅក្នុងមាត្រា៧(ត) មានបទបញ្ញត្តិបែបនេះមួយទៀតដែលរួមបញ្ចូលទាំង "អំពើអមនុស្សធម៌ផ្សេងទៀតដែលមានលក្ខណៈស្រដៀងគ្នាសំដៅបង្កឲ្យមានការឈឺចាប់យ៉ាងខ្លាំង ឬការប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត ឬសុខភាពផ្លូវកាយ"។ ក៏ប៉ុន្តែ បទបញ្ញត្តិប្រហាក់ប្រហែលគ្នានៅក្នុងមាត្រា១៨៨(១១) នៃក្រមព្រហ្មទណ្ឌកម្ពុជា

---

[29] មាត្រា១៨៨ (បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ) ចែងថា៖ "បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ" គឺជាអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនេះ ត្រូវបានប្រព្រឹត្តនៅក្នុងក្របខណ្ឌនៃការវាយលុកជាទូទៅ ឬជា ប្រព័ន្ធសំដៅប្រឆាំងប្រជាជនស៊ីវិល៖

1. ឃាតកម្ម។
2. ការសម្លាប់រង្គាល។
3. ការធ្វើឲ្យទៅជាទាសករ។
4. ការនិរទេស ឬ ជម្លៀសប្រជាជនដោយបង្ខំ។
5. ការដាក់ពន្ធនាគារ ឬគ្រប់រូបភាព ដទៃទៀតនៃការដកហូតយ៉ាងធ្ងន់ធ្ងរនូវសេរីភាពដោយបំពានទៅលើបទបញ្ញត្តិគ្រឹះនៃនីតិអន្តរជាតិ។
6. ការធ្វើទារុណកម្ម។
7. ការចាប់បង្ខំសេពសន្ថវៈ ការធ្វើទាសកម្មខាងផ្លូវភេទ ពេស្យាចារដោយបង្ខំ ការមានគភ៌ដោយបង្ខំ វណ្ណកម្ម ដោយបង្ខំ និងគ្រប់រូបភាពផ្សេងទៀតនៃអំពើហិង្សាខាងផ្លូវភេទ ដែលមានទម្ងន់ប្រហាក់ប្រហែលគ្នា។
8. ការធ្វើទុក្ខបុកម្នេញលើក្រុម ឬសមូហភាព ដោយមូលហេតុនយោបាយ ពូជសាសន៍ ក្រុមជាតិ ជាតិពិន្ទុ វប្បធម៌ សាសនា ឬភេទ។
9. ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ។
10. ការអនុវត្តនយោបាយប្រកាន់ពូជសាសន៍ជាប្រព័ន្ធតាមបែបអាប៉ាថេដ។
11. គ្រប់អំពើអមនុស្សធម៌ផ្សេងទៀត ដែលបង្កឲ្យមានការឈឺចាប់យ៉ាងខ្លាំង ឬ ការប៉ះពាល់ យ៉ាងធ្ងន់ធ្ងរទៅលើបូរណភាពខាងរូបកាយ។

[30] William SCHABAS, *An Introduction to the International Criminal Court* (Cambridge: Cambridge University Press, 2011), at 118.

សំដៅតែទៅលើការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើបូរណភាពខាងរូបកាយប៉ុណ្ណោះ។ ការប៉ះពាល់ធ្ងន់ធ្ងរលើសុខភាពផ្លូវចិត្តពុំត្រូវបានចែងបញ្ចូលឲ្យបានជាក់លាក់នៅក្នុងក្រមនោះទេ។ គេអាចអះអាងថា ការឈឺចាប់ខាងផ្លូវចិត្តអាចដាក់ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌដូចគ្នាតាមរយៈពាក្យ "បង្កឲ្យមានការឈឺចាប់យ៉ាងខ្លាំង"។ម្យ៉ាងវិញទៀត និយាយបានថា អ្នកតាក់តែងច្បាប់នេះមានចេតនាងាកចេញពីនិយមន័យនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ និងមិនដាក់បញ្ចូលលក្ខខណ្ឌតម្រូវនៃការឈឺចាប់ផ្លូវចិត្តនៅក្នុងនិយមន័យនៃក្រមព្រហ្មទណ្ឌកម្ពុជា។ ដូច្នេះ ការឈឺចាប់នេះមិនត្រូវបានចែងបញ្ចូលឡើយ។ នៅចុងក្រោយ មានតែការបកស្រាយ និងការអនុវត្តតាមផ្លូវតុលាការតែប៉ុណ្ណោះដែលអាចបញ្ជាក់បំភ្លឺលើចំណុចវិវាទនេះបាន។ ជាងនេះទៅទៀត និយមន័យនៃការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ និងការប្រកាន់ពូជសាសន៍តាមបែបអាប៉ាថេដ ដូចបានយោងក្នុងមាត្រា៧(១) នៅក្នុងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានកំណត់ដាច់ដោយឡែកពីគ្នានៅក្នុងមាត្រា៧(២)(ខ)(ឆ) និង(ជ) ក៏ប៉ុន្តែ ពុំត្រូវបានចែងបញ្ចូលនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជានោះទេ។ នេះជាការគួរឲ្យសោកស្តាយមួយដោយសារនិយមន័យនេះអាចនឹងជួយបញ្ជាក់បន្ថែមដល់ចៅក្រមជាតិ។ ក្រៅពីភាពខុសគ្នាតិចតួចនេះ ក្រមព្រហ្មទណ្ឌកម្ពុជាភាគច្រើនបានគោរពតាមនិយមន័យនៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិដែលមានចែងនៅក្នុងលក្ខន្តិកទីក្រុងរ៉ូម។

### *គ. បទឧក្រិដ្ឋសង្គ្រាម*

បទឧក្រិដ្ឋសង្គ្រាមមានចែងក្នុងមាត្រា ៨ នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលរួមមានបទបញ្ញត្តិស្តីពីបទឧក្រិដ្ឋសង្គ្រាមជាក់លាក់សរុបចំនួន៧២ បទល្មើស។ មាត្រា៨ នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានបំបែកចេញបន្ថែមឲ្យទៅជាបទឧក្រិដ្ឋសង្គ្រាមដែលអាចអនុវត្តនិនៅក្នុងពេលមានជម្លោះប្រដាប់ជាអាវុធអន្តរជាតិដូចមានចែងក្នុងមាត្រា៨(២)(ក) និង(ខ) នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ និងបទល្មើសនៃបទឧក្រិដ្ឋសង្គ្រាមដែលអនុវត្តនៅអំឡុងពេលនៃជម្លោះប្រដាប់អាវុធដែលមិនមានលក្ខណៈជាអន្តរជាតិ ដូចមានចែងក្នុងមាត្រា៨(២)(ឃ) និង(ង)នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ។ មាត្រា៨(២)(ក)នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិក្តោបរួមទាំងបទបញ្ញត្តិស្តីពីការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ចំនួន៤អនុសញ្ញា។ មាត្រា៨(២)(ខ) នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិបញ្ញត្តិរួមទាំងការបំពារបំពានយ៉ាងធ្ងន់ធ្ងរផ្សេងទៀតលើច្បាប់មនុស្សធម៌អន្តរជាតិដែលអាចអនុវត្តបាននៅអំឡុងពេលនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ដែលត្រូវបានដកស្រង់ចេញមកពីអនុសញ្ញាទីក្រុងហ្សឺណែវ ពិធីសារបន្ថែមទី I អនុសញ្ញាទីក្រុងឡាអេ និងសន្ធិសញ្ញាអន្តរជាតិផ្សេងទៀត[31]។ មាត្រា៨(២)(ឃ) នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិបញ្ចូលរួមទាំងមាត្រា៣រួម ស្តីពីការបំពារបំពានលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ មាត្រា៨(២)(ង) នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ

[31] Michael COTTIER, Article 8(2)(b), in Otto TRIFFTERER, *Commentary on the Rome Statute of the International Criminal Court* (München: C.H.Beck Verlag, 2008) កថាខណ្ឌ ៣០។

បញ្ញត្តិអំពីការបំពារបំពានយ៉ាងធ្ងន់ធ្ងរផ្សេងទៀតលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលអាចអនុវត្តបាននៅអំឡុងពេលនៃជម្លោះប្រដាប់អាវុធដែលមិនមានលក្ខណៈជាអន្តរជាតិ។

ក្រមព្រហ្មទណ្ឌកម្ពុជាកំណត់និយមន័យនៃបទឧក្រិដ្ឋសង្គ្រាមនៅក្នុងមាត្រា១៩៣ និងមាត្រា១៩៤។ មាត្រា១៩៣ នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាភាគច្រើនដូចគ្នាទៅនឹងបទបញ្ញត្តិស្តីពីការបំពារបំពានយ៉ាងធ្ងន់ធ្ងរដែលមានចែងនៅក្នុងមាត្រា៨(២)(ខ) នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ[32]។ ទោះបីជាយ៉ាងនេះក៏ដោយ មាត្រានេះពុំយោងឲ្យបានច្បាស់លាស់លើបទបញ្ញត្តិស្តីពីការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ឬអនុសញ្ញាទីក្រុងហ្សឺណែវនោះទេ។ ម្យ៉ាងវិញទៀត មាត្រានេះពុំតម្រូវឲ្យមានការបែងចែករវាងបទល្មើស ដែលត្រូវបានប្រព្រឹត្តឡើងនៅអំឡុងពេលនៃជម្លោះប្រដាប់អាវុធអន្តរជាតិ និងជម្លោះប្រដាប់អាវុធដែលមិនមានលក្ខណៈជាអន្តរជាតិឡើយ។ ដូច្នេះបទល្មើសទាំងនេះអាចអនុវត្តបាននៅក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធដែលមិនមានលក្ខណៈជាអន្តរជាតិបានដូចគ្នា។ បន្ថែមពីលើនេះ បទល្មើសដូចបានគូសបញ្ជាក់ទាំងអស់នេះ បើទោះជាមានលក្ខណៈស្រដៀងគ្នាក៏ដោយ ក៏វាពុំមានពាក្យពេចន៍ដូចគ្នាបេះបិទនឹងពាក្យពេចន៍ក្នុងមាត្រា៨(២)(ខ) នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិនោះដែរ។ តារាងខាងក្រោមនេះប្រៀបធៀបបទបញ្ញត្តិទាំងនេះ និងបង្ហាញចំណុចខុសគ្នាខ្លាំងបំផុតរវាងមាត្រា៨(២)(ខ) នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌកម្ពុជា និងមាត្រា១៩៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា។ ចំណុចកែប្រែច្រើននៅក្នុងបទបញ្ញត្តិនៃក្រមព្រហ្មទណ្ឌកម្ពុជាត្រូវបានគូសបន្ទាត់ពីខាងក្រោម៖

[32] មាត្រា១៩៣ (បទឧក្រិដ្ឋសង្គ្រាម) ចែងថា "បទឧក្រិដ្ឋសង្គ្រាម" គឺជាអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនោះត្រូវបានប្រព្រឹត្តប្រឆាំងនឹងបុគ្គល ឬ ទ្រព្យសម្បត្តិដែលការពារដោយអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩៖

1. ឃាតកម្ម។
2. ទារុណកម្ម ឬ គ្រប់អំពើអមនុស្សធម៌ រួមបញ្ចូលទាំងការពិសោធជីវសាស្ត្រ។
3. អំពើបង្កដោយចេតនានូវការឈឺចាប់ ឬ ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បូរណភាពខាងរូបកាយ ឬ សុខភាព។
4. ការបំផ្លាញ ឬ ការធ្វើឲ្យខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិ ដោយគ្មានហេតុផលចាំបាច់ខាងយោធា និងក្នុង ទ្រង់ទ្រាយធំ ដោយខុសច្បាប់ និងតាមទំនើងចិត្ត។
5. អំពើបង្ខំឈ្លើយសឹក ឬ ជនស៊ីវិលឲ្យបម្រើក្នុងកងកម្លាំងប្រដាប់អាវុធរបស់សត្រូវ។
6. អំពើដកហូតសិទ្ធិរបស់ឈ្លើយសឹក ឬ ជនស៊ីវិល ក្នុងការទទួលបានការវិនិច្ឆ័យដោយត្រឹមត្រូវ និងឥតលម្អៀង។
7. ជម្លៀស ការបញ្ជូន ឬ ការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់។
8. ការចាប់ជនស៊ីវិលជាចំណាប់ខ្មាំង។"

**<u>តារាងទី ១</u>**

| <u>មាត្រា ៨២(២)(ក) នៃលក្ខន្តិកទីក្រុងរ៉ូម</u> | <u>មាត្រា ១៩៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា</u> |
|---|---|
| ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ១៩៤៩ គឺជាអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនោះត្រូវបានប្រព្រឹត្តប្រឆាំងនឹងបុគ្គល ឬទ្រព្យសម្បត្តិដែលត្រូវបានការពារក្រោមបទបញ្ញត្តិនៃអនុសញ្ញាទីក្រុងហ្សឺណែវដែលពាក់ព័ន្ធ៖ | "បទឧក្រិដ្ឋសង្គ្រាម" គឺជាអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនោះត្រូវបានប្រព្រឹត្តប្រឆាំងនឹងបុគ្គល ឬទ្រព្យសម្បត្តិដែលការពារដោយអនុសញ្ញាក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩៖ |
| (i) ការសម្លាប់ដោយចេតនា។ | (១) ឃាតកម្ម។ |
| (ii) ទារុណកម្ម ឬ គ្រប់អំពើអមនុស្សធម៌ រួមបញ្ចូលទាំងការពិសោធជីវសាស្ត្រ។ | (២) ទារុណកម្ម ឬ គ្រប់អំពើអមនុស្សធម៌ រួមបញ្ចូលទាំងការពិសោធជីវសាស្ត្រ។ |
| (iii) អំពើបង្កដោយចេតនានូវការឈឺចាប់ ឬ ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បូរណភាពខាងរូបកាយ ឬ សុខភាព។ | (៣) អំពើបង្កដោយចេតនានូវការឈឺចាប់ ឬ ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បូរណភាពខាងរូបកាយ ឬ សុខភាព។ |
| (iv) ការបំផ្លាញ ឬការធ្វើឲ្យខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិ ដោយគ្មានហេតុផលចាំបាច់ខាងយោធា និងក្នុងទ្រង់ទ្រាយធំដោយខុសច្បាប់ និងតាមទំនើងចិត្ត។ | (៤) ការបំផ្លាញ ឬការធ្វើឲ្យខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិ ដោយគ្មានហេតុផលចាំបាច់ខាងយោធា និងក្នុងទ្រង់ទ្រាយធំដោយខុសច្បាប់ និងតាមទំនើងចិត្ត។ |
| (v) អំពើបង្ខំឈ្លើយសឹក ឬ | (៥) អំពើបង្ខំឈ្លើយសឹក ឬ <u>ជនស៊ីវិល</u> |

| | | | |
|---|---|---|---|
| | បុគ្គលដែលត្រូវបានការពារផ្សេងទៀតឲ្យបម្រើក្នុងកងកម្លាំងប្រដាប់អាវុធរបស់សត្រូវ។ | | ឲ្យបម្រើក្នុងកងកម្លាំងប្រដាប់អាវុធរបស់សត្រូវ។ |
| (vi) | អំពើដកហូតដោយចេតនានូវសិទ្ធិរបស់ឈ្លើយសឹក ឬ បុគ្គលដែលត្រូវបានការពារ ក្នុងការទទួលបានការវិនិច្ឆ័យដោយត្រឹមត្រូវ និងឥតម្អៀង។ | (៦) | អំពើដកហូតសិទ្ធិរបស់ឈ្លើយសឹក ឬ ជនស៊ីវិល ក្នុងការទទួលបានការវិនិច្ឆ័យដោយត្រឹមត្រូវ និងឥតលម្អៀង |
| (vii) | ជម្លៀស ការបញ្ជូន ឬការឃុំឃាំងដោយខុសច្បាប់។ | (៧) | ជម្លៀស ការបញ្ជូន ឬការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់។ |
| (viii) | ការចាប់ជាចំណាប់ខ្មាំង។ | (៨) | ការចាប់ជនស៊ីវិលជាចំណាប់ខ្មាំង។ |

ការប្រៀបធៀបបានបង្ហាញឲ្យឃើញថា ពាក្យ "បុគ្គលដែលត្រូវបានការពារ" ក្នុងមាត្រា ៨(២)(ខ) នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានកែមកជា "ជនស៊ីវិល" ក្នុងមាត្រា ១៩៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា។ យើងពុំយល់ច្បាស់ទាស់តែសោះថាហេតុអ្វីបានជាអ្នកតាក់តែងច្បាប់របស់កម្ពុជាកែប្រែនិយមន័យនេះ ពីព្រោះថាហេតុផលនៃការធ្វើច្បាប់ពុំត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅក្នុងប្រទេសកម្ពុជានោះទេ។ ទោះបីជាយ៉ាងនេះក្តី ការកែប្រែនេះអាចពន្យល់ប្រាប់យើងបាន ប្រសិនបើយើងលុបចេញនូវចំណុចយោងស្តីពីរបបនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរ និងតាមរយៈករណីដែលថា មាត្រា១៩៣ នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាពុំធ្វើការបែងចែករវាងលក្ខណៈនៃជម្លោះប្រដាប់អាវុធ ពោលគឺ រវាងលក្ខណៈអន្តរជាតិ ឬលក្ខណៈមិនមែនអន្តរជាតិ។ "បុគ្គលដែលត្រូវបានការពារ" និង"ជនស៊ីវិល" គឺជាពាក្យដែលមានអត្ថន័យជាក់លាក់ ហើយវាអាចបញ្ជាក់ថាតើបុគ្គលណាខ្លះដែលត្រូវបានការពារនៅក្រោមច្បាប់មនុស្សធម៌អន្តរជាតិ។ ពាក្យថា "បុគ្គលដែលត្រូវបានការពារ" អនុលោមតាមអនុសញ្ញាទីក្រុងហ្សឺណែវ សំដៅលើបុគ្គលចំនួនបួនប្រភេទ ពោលគឺ អ្នកជំងឺ និងអ្នកមានរបួស បុគ្គលិកពេទ្យ ឈ្លើយសឹក និងជនស៊ីវិល។ ការបែងចែកនេះត្រូវបានគូសបញ្ជាក់តាមរយៈមាត្រា៤(១) នៃអនុសញ្ញាទីក្រុងហ្សឺណែវទី IV ដែលបានកំណត់និយមន័យលើពាក្យ បុគ្គលដែលត្រូវបានការពារ ថាជា "បុគ្គលទាំងឡាយណាដែលទោះបីស្ថិតនៅក្នុងកាលៈទេសៈណាមួយ ឬ នៅក្នុងករណីណាមួយក៏ដោយ យល់ឃើញថា នៅក្នុងពេលមានជម្លោះ ឬនៅក្នុងពេលមានការចូលកាន់កាប់ ខ្លួនស្ថិតនៅក្នុងកណ្តាប់ដៃនៃភាគីមានជម្លោះ ឬអ្នកកាន់កាប់អំណាចដែលខ្លួនពុំមែនជាជាតិសាសន៍ដូចអ្នកកាន់អំណាចនោះ"។ ពាក្យ

"ជនស៊ីវិល" ត្រូវបានកំណត់និយមន័យយ៉ាងច្បាស់ក្នុងមាត្រា៥០ នៅក្នុងពិធីសារបន្ថែមទីI នៃអនុសញ្ញាទីក្រុងហ្សឺណែវថា៖

*"ជនស៊ីវិលគឺជាបុគ្គលទាំងឡាយណាដែលពុំមែនជាប្រភេទបុគ្គលដូចបានកំណត់ក្នុងមាត្រា៤ ក(១) (២) (៣) និង(៦) នៅក្នុងអនុសញ្ញាទីIII និងមាត្រា៤៣ នៅក្នុងពិធីសារនេះ។ នៅក្នុងករណីមានមន្ទិលសង្ស័យថាតើជនណាមួយជាជនស៊ីវិល ឬក៏អត់នោះ ជននេះត្រូវចាត់ទុកថាជាជនស៊ីវិល"។*

មាត្រា៤(ក)(១) (២) (៣) និង (៦) ក្នុងអនុសញ្ញាទីក្រុងហ្សឺណែវទីIII សំដៅលើសមាជិកទាំងឡាយណា កងយុទ្ធពល ឬ កងស្ម័គ្រចិត្តនៅក្នុង ឬជាផ្នែកមួយនៃកម្លាំងប្រដាប់អាវុធ សមាជិកកងយុទ្ធពល និងសមាជិកកងស្ម័គ្រចិត្តផ្សេងទៀតនៃភាគីជម្លោះ និងកំពុងប្រតិបត្តិការណ៍នៅក្នុង ឬនៅក្រៅដែនដីរបស់ខ្លួន ប្រសិនបើកងយុទ្ធពល ឬកងស្ម័គ្រចិត្តទាំងនេះបំពេញលក្ខខណ្ឌប្រយុទ្ធចំនួនបួនលក្ខខណ្ឌ។ ច្បាប់មនុស្សធម៌អន្តរជាតិដែលអនុវត្តចំពោះជម្លោះប្រដាប់អាវុធដែលមិនមានលក្ខណៈជាអន្តរជាតិពុំបានបែងចែកឲ្យបានច្បាស់រវាងយុទ្ធជនប្រយុទ្ធ និងជនស៊ីវិលនោះទេ ក៏ប៉ុន្តែច្បាប់នេះបានបែងចែករវាងបុគ្គលដែលបានចូលរួម ឬពុំបានចូលរួមយ៉ាងសកម្មនៅក្នុងអារិភាព នៅពេលពិចារណាចំពោះការផ្តល់ការការពារដល់អ្នកទាំងនោះ។ ការដែលសំដៅតែទៅលើជនស៊ីវិលដូច្នេះ មានន័យថា មាត្រា១៩៣ ពុំដាក់បញ្ចូលបុគ្គលផ្សេងទៀតដែល ជាធម្មតាអាចស្វែងរកការការពារអនុលោមតាមច្បាប់មនុស្សធម៌អន្តរជាតិ និងលក្ខន្តិកនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនោះទេ។

ការបកស្រាយនេះពុំបានធ្វើឡើងស្របតាមបទបញ្ញត្តិស្តីពីការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដោយសារថា មាត្រា១៩៣(៥) និង (៦) ត្រូវគ្នានឹងការការពារដែលត្រូវបានផ្តល់ជូនដោយឡែកពីគ្នាដល់បុគ្គលទាំងឡាយដូចបានកំណត់ក្នុងមាត្រា១២៩ នៃអនុសញ្ញាទីក្រុងហ្សឺណែវទីIII (ពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះឈ្លើយសឹកសង្គ្រាម) និងមាត្រា១៤៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវទីIV (ពាក់ព័ន្ធនឹងការការពារជនស៊ីវិលនៅក្នុងពេលសង្គ្រាម)។ ទោះបីជាយ៉ាងនេះក្តី ដោយសារថាក្រមព្រហ្មទណ្ឌកម្ពុជាពុំបានយកលក្ខណៈនៃជម្លោះប្រដាប់អាវុធមកពិចារណា បុគ្គលដែលត្រូវបានការពារផ្សេងទៀតអាចមិនត្រូវបានដាក់បញ្ចូលនៅក្នុងក្រមនេះ។ លើសពីនេះ លក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិហាក់ដូចជាពន្លាតនិយមន័យនៃមាត្រាទាំងពីរនេះដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវទីIII និងIV។ ដូច្នេះ ការបែងចែករវាង "បុគ្គលដែលត្រូវបានការពារ" និង"ជនស៊ីវិល" មាត្រា១៩៣(៥) (៦) និង(៧) នៃក្រមព្រហ្មទណ្ឌកម្ពុជាត្រូវបានកំណត់និយមន័យយ៉ាងចង្អៀតជាងបទបញ្ញត្តិស្រដៀងគ្នា ដែលមានចែងនៅក្នុងលក្ខន្តិកនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយសារថា ការយោងតែទៅលើ"ជនស៊ីវិល" ជំនួសឲ្យបុគ្គលដែលត្រូវបានការពារនឹងមិនគ្របដណ្តប់រួមទាំងការការពារដល់បុគ្គលិកពេទ្យ ឬបុគ្គលិក

សាសនារបស់កងកម្លាំងប្រដាប់អាវុធ[33]។ គេមិនអាចអះអាងថា បុគ្គលដែលត្រូវបានការពារនឹងស្វែងរកការការពារខ្លួនក្នុងនាមជាឈ្លើយសង្គ្រាមនោះទេ ពីព្រោះបុគ្គលិកពេទ្យយោធា និងបុគ្គលិកសាសនាយោធាពុំអាចចាត់ទុកថាជាឈ្លើយសឹកសង្គ្រាមឡើយ[34]។ ដូច្នេះ ការបញ្ចូលពាក្យ "ជនស៊ីវិល" ជំនួស "ឈ្លើយសឹកសង្គ្រាម" នៅក្នុងមាត្រា១៩៣(៨) នៃក្រមព្រហ្មទណ្ឌកម្ពុជា គឺជាការបង្រួមនិយមន័យនៃបទល្មើស នៅពេលប្រៀបធៀបជាមួយនឹងមាត្រា៨(២)(ក) នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ក្រៅពីនេះ ការចាប់ជាចំណាប់ខ្មាំងនៅក្រោមមាត្រា១៩៣(៨) នៃក្រមព្រហ្មទណ្ឌកម្ពុជាអនុវត្តតែទៅលើជនស៊ីវិលតែប៉ុណ្ណោះ។ ការបញ្ញត្តិដូច្នេះគឺពុំស្របទៅតាមមាត្រា ៨(២)(ខ)(៨) នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិទេ ដោយសារ នៅក្រោមច្បាប់កម្ពុជា បុគ្គលដែលត្រូវបានការពារក្រៅពីជនស៊ីវិលពុំត្រូវបានដាក់បញ្ចូលជាកម្មវត្ថុនៃបទល្មើសឡើយ។

បុព្វកថានៃមាត្រា១៩៣ សំដៅលើបុគ្គលដែលត្រូវបានការពារ ហើយបទល្មើសដូចបានរៀបរាប់នោះអាចត្រូវបានពន្លាត និងបកស្រាយទូលាយជាងនេះ។ ក៏ប៉ុន្តែ តាមរយៈការជ្រើសរើសដោយចេតនាក្នុងការផ្លាស់ប្តូរពាក្យដូច្នេះ អ្នកតាក់តែងច្បាប់កម្ពុជាមានបំណងចង់ឲ្យមានការបកស្រាយក្នុងន័យចង្អៀតលើវិធាននេះ[35]។ នៅក្នុងន័យនេះ តុលាការជាតិអាចពិនិត្យមើលគោលការណ៍ណែនាំចេញពីកេរតំណែលយុត្តិសាស្ត្ររបស់ អ.វ.ត.ក ដែលលើកឡើងអំពីបទល្មើសនៃការឃុំឃាំងដោយខុសច្បាប់នៅក្នុងសេចក្តីសម្រេចមួយរបស់ខ្លួន។ ដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ច្បាប់ អ.វ.ត.ក បានកំហិតចំពោះឧក្រិដ្ឋកម្មដែលសំដៅលើជនស៊ីវិល[36] ដូចមានចែងក្នុងមាត្រា១៤៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវទីIV។ ទោះបីជាយ៉ាងនេះក្តី អ.វ.ត.ក ពុំបានកំហិតថា ជនស៊ីវិលគឺជាកម្មវត្ថុនៃបទល្មើសទេ ដូចមានចែងនៅក្នុងមាត្រា៦ នៃច្បាប់ អ.វ.ត.ក។ ប៉ុន្តែ អ.វ.ត.ក បានពង្រីកកម្មវត្ថុនៃបទល្មើសដោយរួមបញ្ចូលទាំងឈ្លើយសឹកសង្គ្រាម និងបុគ្គលផ្សេងទៀត[37]។ ទោះស្ថិតក្នុងករណីណាក៏ដោយ ការអនុវត្តក្នុងន័យចង្អៀតលើមាត្រា១៩៣(៥) ដល់ (៨)នៃក្រមព្រហ្មទណ្ឌកម្ពុជា អាចខ្វាស់គ្នាជាមួយនឹងគោលការណ៍នៃយន្តការបំពេញបន្ថែម ដែលនឹងត្រូវយកមកពិភាក្សាលម្អិតជាងនេះនៅក្នុងចំណុចខាងក្រោម។

---

[33] On the legality of confinement of other protected persons see, Knut DöRMANN, *Elements of War Crimes under the Rome Statute of the ICC* (Cambridge: Cambridge University Press, 2003), at 118-122.

[34] មាត្រា ២៤ ២៥ ២៨ ២៩ នៃអនុសញ្ញាទីក្រុងហ្សឺណែវទីមួយ។ មាត្រា ៣៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវទីពីរ។ មាត្រា ៤៤ នៃពិធីសារបន្ថែមទីពីរនៃអនុសញ្ញាទីក្រុងហ្សឺណែវ។

[35] ដូចបានលើកឡើងខាងលើ ខុសពីរដ្ឋដទៃ ប្រទេសកម្ពុជាពុំ បោះពុម្ពផ្សាយឯកសារពិគ្រោះយោបល់ ឬ មូលហេតុផ្លូវការ របស់សមាជិកសភាស្តីពីច្បាប់ដែលត្រូវបានអនុម័ត។

[36] សូមមើល មាត្រា ៦ នៃច្បាប់ អ.វ.ត.ក។

[37] អ.វ.ត.ក *កាំង ហ្កេកអ៊ាវ* សំណុំរឿង ០០១/១៨-០៧-២០០៧/អវតក/អជសដ សាលក្រម ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤១៧-៤១៩ ៤២៥-៤២៦ ៤៦៨ ហើយចំពោះសមាសភាពនៃជនត្រូវបានឃុំខ្លួន សូមមើលកថាខណ្ឌ ១៤១។

មាត្រា ១៩៤ នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាបានចែងអំពីការរំលោភយ៉ាងធ្ងន់ធ្ងរផ្សេងទៀតលើច្បាប់មនុស្សធម៌អន្តរជាតិ[38]។ នៅពេលពិនិត្យជាលើកដំបូងលើមាត្រា១៩៤នៃក្រមព្រហ្មទណ្ឌកម្ពុជា បានបង្ហាញឲ្យឃើញថា បទល្មើសនៃបទឧក្រិដ្ឋសង្គ្រាមសំខាន់ៗជាច្រើនទៀតពុំត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌឡើយ។ ដូចបានលើកឡើងពីខាងដើម មាត្រា៨ នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិបានដាក់បញ្ចូលបទបញ្ញត្តិចំនួន៦៤ ស្តីពីបទល្មើសនៃបទឧក្រិដ្ឋសង្គ្រាម បន្ថែមលើបទបញ្ញត្តិស្តីពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរចំនួនប្រាំបីជាក់លាក់ដូចបានពិភាក្សាខាងលើ។ លក្ខន្តិកទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបែងចែករវាងបទឧក្រិដ្ឋសង្គ្រាមនៅអំឡុងពេលនៃជម្លោះប្រដាប់អាវុធអន្តរជាតិ និងក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធដែលមិនមានលក្ខណៈជាអន្តរជាតិ ដូច្នេះបទល្មើសជាច្រើនត្រូវបានកំណត់និយមន័យស្រដៀងៗគ្នា។ ភស្តុតាងបានបង្ហាញយ៉ាងច្បាស់ថា មាត្រា១៩៤ នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាពុំបានចាត់ទុកថាជាបទល្មើសជាច្រើនដែលយកចេញមកពីច្បាប់ឡាអេ និងច្បាប់ហ្សឺណែវ ថាជាបទល្មើសព្រហ្មទណ្ឌនោះទេ។ ជាការគួរឲ្យសោកស្តាយ ហេតុផលរបស់អ្នកតាក់តែងច្បាប់ក្នុងការមិនកំណត់បទល្មើសដូច្នេះ ពុំត្រូវបានផ្សព្វផ្សាយជាសាធារណៈឲ្យយើងបានដឹងឡើយ។ តារាងទីពីរខាងក្រោមរៀបរាប់អំពីបទល្មើសនៃបទឧក្រិដ្ឋសង្គ្រាមនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា និងបទបញ្ញត្តិស្រដៀងៗគ្នានៅក្នុងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ។ មិនខុសពីការប្រៀបធៀបខាងលើ មាត្រា១៩៤ ពុំបានប្រើប្រាស់ពាក្យពេចន៍ស្រដៀងគ្នានឹងបទបញ្ញត្តិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិឡើយ។ ដូច្នេះ មានតែបទបញ្ញត្តិស្រដៀងៗគ្នារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិតែប៉ុណ្ណោះដែលត្រូវបានសរសេរបញ្ចូលឡើងវិញនៅក្នុងតារាងខាងក្រោមនេះ។

---

[38] មាត្រា ១៩៤ (បទឧក្រិដ្ឋសង្គ្រាមផ្សេងទៀត) ចែងថា៖ "អំពើណាមួយដូចមានចែងខាងក្រោមនេះ គឺ ជាបទឧក្រិដ្ឋកម្មសង្គ្រាមដែរ កាលបើអំពើនោះត្រូវបានប្រព្រឹត្តក្នុងឱកាសជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិ ឬ មិនមែនអន្តរជាតិ៖

1. ការប្រើប្រាស់អាវុធដែលមានជាតិពុល ឬ អាវុធដែលស្លាបនាឡើងដើម្បីបង្កការឈឺចាប់ឥតប្រយោជន៍។
2. អំពើវាយប្រហារ ឬ ទម្លាក់គ្រាប់បែកដោយចេតនា តាមមធ្យោបាយណាក៏ដោយទៅលើទីក្រុង ភូមិ ទីកន្លែងរស់នៅ ឬ អាគារដែលមិនមានការការពារ និងដែលមិនមែនជាកម្មវត្ថុខាងយោធា។
3. អំពើវាយប្រហារដោយចេតនាទៅលើមនុស្ស ឬ សម្ភារៈ ដែលប្រើប្រាស់ក្នុងក្របខណ្ឌនៃបេសកកម្មមនុស្សធម៌ ដោយអនុលោមតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។
4. អំពើបង្កគ្រោះទុរ្ភិក្សដោយចេតនាដល់ប្រជាជនស៊ីវិល ដោយ ដកហូតនូវទ្រព្យសម្បត្តិចាំបាច់សម្រាប់បន្តរស់រានមានជីវិតរបស់ជនស៊ីវិលទាំងនេះ។
5. អំពើប្រើប្រាស់ជនស៊ីវិលដើម្បីបញ្ចៀសពីគោលដៅនៃប្រតិបត្តិការយោធាទៅលើអាគារខ្លះ តំបន់ខ្លះនៃដែនដី ឬ កង កម្លាំងយោធាខ្លះ
6. អំពើបំផ្លាញ ឬ ធ្វើឲ្យខូចខាតដោយចេតនា នូវអាគារសម្រាប់សាសនា សប្បុរធម៌ អប់រំ សិល្បៈ និងវិទ្យាសាស្ត្រ វិមានប្រវត្តិសាស្ត្រ ស្នាដៃសិល្បៈ ឬ ស្នាដៃដែលមានលក្ខណៈវិទ្យាសាស្ត្រ។
7. អំពើបង្កដល់បរិស្ថានធម្មជាតិនូវការខូចខាតដ៏ធំ យូរអង្វែង និងធ្ងន់ធ្ងរ ដែលមានលក្ខណៈហួសហេតុយ៉ាងជាក់ស្តែង បើប្រៀបទៅនឹងផលប្រយោជន៍ពិតប្រាកដ និងផ្ទាល់ ខាងផ្នែកយោធាដែលសង្ឃឹមទុក។
8. ការលួចប្លន់សម្បត្តិសាធារណៈ ឬ ឯកជន។"

**<u>តារាងទី ២</u>**

| <u>លក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ</u> | <u>មាត្រា ១៩៤ នៃក្រមព្រហ្មទណ្ឌកម្ពុជា</u> |
| --- | --- |
| | អំពើណាមួយដូចមានចែងខាងក្រោមនេះ គឺជាបទឧក្រិដ្ឋកម្មសង្គ្រាមដែរ កាលបើ អំពើនោះត្រូវបានប្រព្រឹត្តក្នុងឱកាស ជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិ ឬ មិនមែនអន្តរជាតិ៖ |
| ការប្រើប្រាស់ជាតិពុល ឬ អាវុធដែលមានជាតិពុល។ **[មាត្រា ៨(២)(ខ) (xvii)]** | (១) ការប្រើប្រាស់អាវុធដែលមានជាតិពុល ឬ អាវុធដែលស្លាបនាឡើងដើម្បីបង្កការឈឺ ចាប់ឥតប្រយោជន៍។ |
| អំពើវាយប្រហារ ឬ ទម្លាក់គ្រាប់បែកតាមមធ្យោបាយណាក៏ដោយទៅលើទីក្រុង ភូមិ ទីកន្លែងរស់នៅ ឬ អាគារដែលមិនមានការការពារ និងដែលមិនមែនជាកម្មវត្ថុខាងយោធា។ **[មាត្រា ៨(២)(ខ)(v)]** | (២) អំពើវាយប្រហារ ឬ ទម្លាក់គ្រាប់បែកដោយចេតនា តាមមធ្យោបាយណាក៏ដោយទៅលើទីក្រុង ភូមិ ទីកន្លែងរស់នៅ ឬ អាគារដែលមិនមានការការពារ និងដែលមិនមែនជាកម្មវត្ថុខាងយោធា។ |
| អំពើសំដៅការវាយប្រហារដោយចេតនាទៅលើបុគ្គលិក ទីតាំង សម្ភារ អង្គភាព ឬ យានយន្តដែលប្រើប្រាស់ក្នុងក្របខណ្ឌនៃជំនួយមនុស្សធម៌ ឬ បេសកកម្មរក្សាសន្តិភាពដោយអនុលោមតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ដរាបណាអ្វីៗទាំងអស់នេះទទួលបានការការពារដូចបានផ្តល់ជូនជនស៊ីវិល ឬ ទ្រព្យសម្បត្តិជនស៊ីវិលអនុលោមតាម | (៣) អំពើវាយប្រហារដោយចេតនាទៅលើមនុស្ស ឬ សម្ភារ ដែលប្រើប្រាស់ក្នុងក្របខណ្ឌនៃបេសកកម្មមនុស្សធម៌ ដោយអនុលោមតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។ |

| | |
|---|---|
| ច្បាប់អន្តរជាតិនៃជម្លោះប្រដាប់អាវុធ **[មាត្រា ៨(២)(ង) និង (ខ)(iii)]** | |
| អំពើប្រើប្រាស់ការបង្អត់អាហារដល់ជនស៊ីវិល ដើម្បីជាមធ្យោបាយសង្គ្រាមដោយដកហូតនូវទ្រព្យសម្បត្តិចាំបាច់សម្រាប់បន្តរស់រានមានជីវិតរបស់ជនស៊ីវិលទាំងនេះ រួមទាំងការរារាំងការផ្គត់ផ្គង់ជំនួយសង្គ្រោះដោយចេតនា ដូចមានចែងនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ។ **[មាត្រា ៨ (២)(ខ)(iv)]** | (៤) អំពើបង្កគ្រោះទុរ្ភិក្សដោយចេតនាដល់ប្រជាជនស៊ីវិល ដោយ ដកហូតនូវទ្រព្យសម្បត្តិចាំបាច់សម្រាប់បន្តរស់រានមានជីវិតរបស់ជនស៊ីវិលទាំងនេះ។ |
| អំពើប្រើប្រាស់វត្តមានជនស៊ីវិល ឬ បុគ្គលដែលត្រូវបានការពារផ្សេងទៀតដើម្បីបញ្ចៀសពីគោលដៅនៃប្រតិបត្តិការយោធាទៅលើទីតាំង តំបន់ ឬ កងកម្លាំងយោធា។ **[មាត្រា ៨ (២)(ខ)(xxiii)]** | (៥) អំពើប្រើប្រាស់ជនស៊ីវិលដើម្បីបញ្ចៀសពីគោលដៅនៃប្រតិបត្តិការយោធាទៅលើអាគារខ្លះ តំបន់ខ្លះនៃដែនដី ឬ កងកម្លាំងយោធាខ្លះ។ |
| អំពើសំដៅការវាយប្រហារដោយចេតនាលើអាគារសម្រាប់សាសនា អប់រំ សិល្បៈ វិទ្យាសាស្ត្រ ឬ សប្បុរធម៌ វិមានប្រវត្តិសាស្ត្រ មន្ទីរពេទ្យ និងទីកន្លែងដែលប្រមូលផ្ដុំដោយអ្នកឈឺ និងមានរបួស ក្នុងករណីដែលពួកគេពុំមែនជាគោលដៅយោធា។ **[មាត្រា ៨ (២)(ខ)(ix)]** | (៦) អំពើបំផ្លាញ ឬ ធ្វើ ឲ្យខូចខាតដោយចេតនា នូវអាគារសម្រាប់សាសនា សប្បុរធម៌ អប់រំ សិល្បៈ និងវិទ្យាសាស្ត្រ វិមានប្រវត្តិសាស្ត្រ ស្នាដៃសិល្បៈ ឬ ស្នាដៃដែលមានលក្ខណៈវិទ្យាសាស្ត្រ។ |
| អំពើវាយប្រហារដោយចេតនាដោយដឹងថាការវាយប្រហារនោះនឹងបណ្ដាលដោយ | (៧) អំពើបង្កដល់បរិស្ថានធម្មជាតិនូវការខូចខាតដ៏ធំ យូរ អង្វែង និង ធ្ងន់ធ្ងរដែលមានលក្ខណៈហួសហេតុយ៉ាង |

| | |
|---|---|
| បាត់បង់ជីវិតមនុស្សជាយថាហេតុ ឬ បង្ករបួសដល់ជនស៊ីវិល ឬ ការខូចខាតដល់ទ្រព្យសម្បត្តិរបស់ជនស៊ីវិល ឬ ការខូចខាតដ៏ធំ យូរអង្វែង និងធ្ងន់ធ្ងរដល់បរិស្ថានធម្មជាតិដែលមានលក្ខណៈហួសហេតុយ៉ាងជាក់ស្តែងបើប្រៀបទៅនឹងផលប្រយោជន៍ពិតប្រាកដ និងផ្ទាល់ ខាងផ្នែកយោធាដែលសង្ឃឹមទុក។ **[មាត្រា ៨ (២)(ខ)(iv)]** | ជាក់ស្តែង បើ ប្រៀបទៅនឹងផលប្រយោជន៍ពិតប្រាកដ និងផ្ទាល់ ខាង ផ្នែកយោធាដែលសង្ឃឹមទុក។ |
| ការលួចប្លន់ទីក្រុង ឬ ទីកន្លែងណាមួយ មិនថាត្រូវបានវាយដណ្តើមយកដោយការវាយប្រហារក៏ដោយ។ **[មាត្រា ៨ (២)(ខ)(xvi) និង (ង)(v)]** | (៨) ការលួចប្លន់សម្បត្តិសាធារណៈ ឬឯកជន។ |

ជាថ្មីម្តងទៀត បទបញ្ញត្តិនៅក្នុងមាត្រា១៩៤ នៃក្រមព្រហ្មទណ្ឌកម្ពុជាបានប្រើប្រាស់ពាក្យពេចន៍ប្រកបដោយភាពចម្រូងចម្រាស និងគ្រោះថ្នាក់នៅពេលប្រើប្រាស់បទល្មើសខុសពីបទល្មើសដែលមានចែងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ឧទាហរណ៍ មាត្រា១៩៤(៣) ខុសគ្នាយ៉ាងខ្លាំងពីបទបញ្ញត្តិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ លក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិកំណត់ថា ការវាយប្រហារលើជំនួយមនុស្សធម៌ និងបេសកកម្មរក្សាសន្តិភាពស្របតាមធម្មនុញ្ញនៃអង្គការសហប្រជាជាតិគឺជាបទល្មើសព្រហ្មទណ្ឌ "ដរាបណាជំនួយ និងបេសកកម្មទាំងនេះទទួលបាននូវការការពារដូចត្រូវបានផ្តល់ជូនជនស៊ីវិល និងវត្ថុរបស់ជនស៊ីវិលក្រោមច្បាប់មនុស្សធម៌នៃជម្លោះប្រដាប់អាវុធ"។ មាត្រា១៩៤(៣) ពុំបានតម្រូវថា បេសកកម្មមនុស្សធម៌ ឬបេសកកម្មរក្សាសន្តិភាពត្រូវតែទទួលបាននូវការការពារដូចត្រូវបានផ្តល់ជូនជនស៊ីវិល និងវត្ថុរបស់ជនស៊ីវិលនោះទេ ប៉ុន្តែ មាត្រានេះហាក់ដូចជាចង់មានន័យថា ការវាយប្រហារណាក៏ដោយ ទោះបីជាពុំទទួលបាននូវការការពារ នៅតែជាបទល្មើសព្រហ្មទណ្ឌ។ នៅត្រង់ចំណុចនេះហើយដែលបទបញ្ញត្តិនៅក្នុងច្បាប់កម្ពុជាកំណត់ហួសពីលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[39] ដោយហេតុថា ការវាយប្រហារប្រឆាំងនឹងបុគ្គលិករក្សាសន្តិភាពដែលបានចូលរួមយ៉ាងសកម្មនៅក្នុងអរិភាពប្រឆាំងនឹងបដិបក្ខសង្គ្រាមមិនអាចចាត់ទុកជាបទឧក្រិដ្ឋ

[39] ចំពោះឋានៈនៃបទល្មើស សូមមើល រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង SESAY, KALLON, GBAO*, រឿងក្តីលេខ SCSL-04-15, សាលក្រម, ចុះថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ២១៥-២១៨។

សង្គ្រាម[40]។ មាត្រា១៩៤(៥) សំដៅលើ "ជនស៊ីវិល" ថាត្រូវបានប្រើប្រាស់ជាខែលការពារ ប៉ុន្តែពុំកំណត់ថាការធ្វើដូច្នេះលើបុគ្គលដែលត្រូវបានការពារផ្សេងទៀត គឺជាបទល្មើសព្រហ្មទណ្ឌឡើយ[41]។ ដូចបានលើកឡើងខាងលើ នៅក្នុងបរិបទនេះ បទបញ្ញត្តិនៃក្រមព្រហ្មទណ្ឌកម្ពុជាវិវឌ្ឍឃើតជាងនិយមន័យនៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយសារការប្រើប្រាស់កម្មវត្ថុផ្សេងនៃបទល្មើសក្រៅពីជនស៊ីវិល ហាក់ដូចជាអាចធ្វើឡើងដោយស្របច្បាប់នៅក្រោមមាត្រា១៩៤(៥)។ មាត្រា១៩៤(៦) នៃក្រមព្រហ្មទណ្ឌកម្ពុជាពុំបានទាមទារនូវលក្ខខណ្ឌថា តំបន់ទទួលការការពារពុំត្រូវបានប្រើប្រាស់សម្រាប់គោលបំណងយោធានោះឡើយ ហើយមាត្រានេះមានលក្ខណៈចង្អៀតខ្លាំងជាងបទបញ្ញត្តិនៅក្នុងមាត្រា៨(២)(ខ) និង(ង)(ix) នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ដូច្នេះ មាត្រានេះកម្រិតការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើមួយចំនួនជាក់លាក់ប៉ុណ្ណោះ[42]។ ម្យ៉ាងវិញទៀត មានបញ្ហាចោទថាតើមាត្រា១៩៤(៦) បានគោរពតាមច្បាប់មនុស្សធម៌អន្តរជាតិដែរឬទេ នៅពេលដែលកម្មវត្ថុដូចដែលបានរៀបរាប់នោះអាចបាត់បង់នូវសិទ្ធិទទួលបានការការពារនោះ[43]។

ក្រៅពីចំណុចខុសគ្នានេះ វាកាន់តែធ្វើឲ្យយើងព្រួយបារម្ភនៅពេលដែលក្រមព្រហ្មទណ្ឌកម្ពុជាពុំបានចែងអំពីការរំលោភយ៉ាងធ្ងន់ធ្ងរជាច្រើនផ្សេងទៀតលើច្បាប់មនុស្សធម៌អន្តរជាតិដូចមានចែងនៅក្នុងលក្ខន្តិកៈ តុលាការព្រហ្មទណ្ឌអន្តរជាតិថាជាបទល្មើសព្រហ្មទណ្ឌ។ ឧទហរណ៍ ក្រមព្រហ្មទណ្ឌកម្ពុជាពុំកំណត់បទល្មើសព្រហ្មទណ្ឌចំពោះ៖ ការវាយប្រហារដោយចេតនាលើប្រជាជនស៊ីវិល[44] ឬវត្ថុរបស់ជនស៊ីវិល[45] ការប្រើប្រាស់ទង់ស គ្រឿងសម្គាល់ ឬ បដិរូបដោយមិនត្រឹមត្រូវ[46] ការប្រកាសថា គ្មានតំបន់ណាមួយត្រូវបានផ្តល់ឲ្យនោះទេ[47] ការលុបបំបាត់សិទ្ធិ និងកាតព្វកិច្ចរបស់ពលរដ្ឋនៃភាគីជម្លោះ[48] ការប្រើប្រាស់អាវុធហាមឃាត់[49] ការវាយប្រហារលើបុគ្គលនិងវត្ថុដែលបានប្រើប្រាស់បដិរូប ពិសេសនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ អនុលោមតាមច្បាប់អន្តរជាតិ[50] ឬការចាប់ទាហាន ការឲ្យ ឬការប្រើប្រាស់កុមារក្រោមអាយុ១៥ឆ្នាំ ឲ្យចូលរួមប្រយុទ្ធ

---

[40] *ដូចខាងលើ* កថាខណ្ឌ ២៣១។

[41] Knut DÖRMANN, លេខយោងជើងទំព័រ ៣៣ *ដូចខាងលើ* ត្រង់ទំព័រ ៣៤៦ ៣៤៧។

[42] Knut DÖRMANN, លេខយោងជើងទំព័រ ៣៣ *ដូចខាងលើ* ត្រង់ទំព័រ ២២៧។

[43] សូមមើល មាត្រា ៥២(៣) នៃពិធីសារបន្ថែមនៃអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងពាក់ព័ន្ធនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធ ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៧៧ 1125 UNTS 3។

[44] មាត្រា ៨(២)(ខ)(i) និង (ង)(i) នៃលក្ខន្តិករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[45] មាត្រា ៨(២)(ខ)(ii) និង (ង)(ii) នៃលក្ខន្តិករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[46] មាត្រា ៨(២)(ខ)(vii) នៃលក្ខន្តិករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[47] មាត្រា ៨(២)(ខ)(xii) និង (ង)( និង (ង)(គ) នៃលក្ខន្តិករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[48] មាត្រា ៨(២)(ខ)(xiv) នៃលក្ខន្តិករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[49] មាត្រា ៨(២)(ខ)(xix) និង (xx) នៃលក្ខន្តិករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[50] មាត្រា ៨(២)(ខ)(xxii) នៃលក្ខន្តិករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

ក្នុងជម្លោះ[51]។ ការលុបចោលឃ្លាទាំងអស់នេះ គឺជាការគួរឲ្យសោកស្ដាយ ដោយសាររដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងអំពីការការពារកុមារនៅក្នុងអំឡុងពេលមានសង្គ្រាម[52]។ ម៉្យាងវិញទៀត ក្រមព្រហ្មទណ្ឌកម្ពុជាពុំបានកំណត់បទល្មើសព្រហ្មទណ្ឌឲ្យបានច្បាស់ចំពោះបទល្មើសផ្លូវភេទដូចមានចែងនៅក្នុងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ[53]។ ទោះបីជាការប្រព្រឹត្តបែបនេះអាចស្ថិតនៅក្រោមមាត្រា១៩៣(២) ឬ(៣) នៃក្រមព្រហ្មទណ្ឌកម្ពុជាក៏ដោយ ពោលគឺ ការធ្វើទារុណកម្ម ឬគ្រប់អំពើអមនុស្សធម៌ ឬអំពើបង្កដោយចេតនានូវការឈឺចាប់[54] ក៏ការពុំបញ្ញត្តិអំពើទាំងនេះឲ្យបានច្បាស់លាស់បង្កើតឲ្យមានការលំបាកពាក់ព័ន្ធនឹងគោលការណ៍នៃយន្តការបំពេញបន្ថែម។

ដូចបានពិភាក្សារួចមកហើយ ពាក្យពេចន៍ និងនិយមន័យខ្លះនៅក្នុងមាត្រា១៩៤ ត្រូវបានកែសម្រួល ធ្វើឲ្យបទល្មើសនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាត្រូវបានបកស្រាយក្នុងន័យចង្អៀតជាងបទល្មើសដូចមានចែងនៅក្នុងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ម្យ៉ាងវិញទៀត ច្បាប់កម្ពុជាពុំដាក់បញ្ចូលបទល្មើសនៃបទឧក្រិដ្ឋសង្គ្រាមដែលឃើញមាននៅក្នុងមាត្រា៨ នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិថាជាបទល្មើសព្រហ្មទណ្ឌឡើយ។ ករណីនេះធ្វើឲ្យមានការព្រួយបារម្ភថា តើប្រព័ន្ធតុលាការកម្ពុជាមានលទ្ធភាពចោទប្រកាន់ដាក់ទោសបទល្មើសនៃបទឧក្រិដ្ឋសង្គ្រាមមួយចំនួនបានដែរឬយ៉ាងណា ហើយថាប្រសិនបោះដូច្នោះមែនវានឹងបង្កើតជា "ការមិនមានលទ្ធភាព" អនុលោមតាមមាត្រា១៧(៣) នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ទោះបីជានៅក្នុងកាលៈទេសៈមួយចំនួន ចៅក្រមអាចមានឆន្ទានុសិទ្ធិបកស្រាយបទបញ្ញត្តិទាំងនេះឲ្យស្របតាមលក្ខន្តិកទីក្រុងរ៉ូម និង/ឬ ច្បាប់មនុស្សធម៌អន្តរជាតិស្របតាមមាត្រា៨នៃក្រមព្រហ្មទណ្ឌកម្ពុជានិងមាត្រា៣១នៃរដ្ឋធម្មនុញ្ញកម្ពុជាយ៉ាងណាក៏ដោយ ក៏ឆន្ទានុសិទ្ធិនេះអនុញ្ញាតឲ្យត្រឹមតែបកស្រាយទៅតាមការកំណត់នៅក្នុងមាត្រា៣នៃក្រមព្រហ្មទណ្ឌកម្ពុជា និងគោលការណ៍*គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង* តែប៉ុណ្ណោះ។ ផលប៉ះពាល់នៃការយកលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិមកចែងបញ្ចូលជាច្បាប់ជាតិ ដោយនៅមានភាពខ្វះចន្លោះបែបនេះនឹងត្រូវយកមកពិចារណានៅក្នុងផ្នែក V ខាងក្រោម។

---

[51] មាត្រា ៨(២)(ខ)(xxvi) និង (ង)(vii) នៃលក្ខន្តិករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[52] សូមមើល មាត្រា ៤៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថា៖ "រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឲ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬ ដែលនាំឲ្យអន្តរាយដល់សុខភាព ឬ សុខុមាលភាពរបស់កុមារ"។

[53] មាត្រា ៨(២)(ខ)(xxii) និង (ង)(vi) នៃលក្ខន្តិករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[54] សូមមើល អ.វ.ត.ក *កាំង ហ្កេកអ៊ាវ* សំណុំរឿង ០០១/១៨-០៧-២០០៧/អវតក/អជសជ សាលក្រម ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៦៦ ដែលលើកឡើងថា ការរំលោភសេពសន្ថវៈអាចចាត់ទុកថាជាអំពើទារុណកម្ម។ ទោះបីជាការសម្រេចបែបនេះធ្វើឡើងពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏ការសន្និដ្ឋាននេះគឺអនុវត្តបានដូចគ្នាចំពោះបទប្បញ្ញត្តិនៃឧក្រិដ្ឋកម្មសង្គ្រាម។

## III. ទម្រង់នៃការទទួលខុសត្រូវនិងការការពារខ្លួន

បទបញ្ញត្តិទូទៅនៅក្នុងគន្ថីទី១ មាតិកាទី១ ជំពូកទី១ នៃក្រមព្រហ្មទណ្ឌកម្ពុជាអនុវត្តចំពោះទម្រង់នៃការទទួលខុសត្រូវលើឧក្រិដ្ឋកម្មអន្តរជាតិ។ ទម្រង់នៃការទទួលខុសត្រូវនេះត្រូវបានកំណត់និយមន័យនៅក្នុងមាត្រា២៤ ដល់មាត្រា២៩ នៃក្រមព្រហ្មទណ្ឌកម្ពុជា និងចែងរួមទាំងចារី (មាត្រា២៥) សហចារី (មាត្រា២៦) អ្នកផ្តើមគំនិត (មាត្រា២៨) និងការទទួលខុសត្រូវរបស់អ្នកសមគំនិតផងដែរ ពោលគឺ ការជួយ និងជំរុញ (មាត្រា៣០)។ អំពើប៉ុនប៉ងក៏ត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌដែរនៅក្នុងមាត្រា២៧នៃក្រមព្រហ្មទណ្ឌកម្ពុជា។ ការរៀបចំផែនការលើបទឧក្រិដ្ឋប្រល័យពូជសាសន៍ត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌនៅក្នុងមាត្រា១៨៥ នៃក្រមព្រហ្មទណ្ឌកម្ពុជា។ មាត្រានេះចែងថា ការចូលរួមនៅក្នុងក្រុមណាមួយ ឬនៅក្នុងការឃុបឃិតណាមួយដើម្បីរៀបចំផែនការប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជាសាសន៍ត្រូវដាក់ទោសឲ្យជាប់ពន្ធនាគារពី២០ ទៅ៣០ឆ្នាំ[55]។ មិនខុសពីលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ បទបញ្ញត្តិនេះពុំទាមទារឲ្យមានលក្ខខណ្ឌនៃការប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍ជាក់លាក់នោះទេ ហេតុដូច្នេះ វាជាទម្រង់នៃការទទួលខុសត្រូវចំពោះអំពើមិនបានសម្រេច។ បទបញ្ញត្តិនេះ ក៏ឆ្លុះបញ្ចាំង នៅក្នុងការកំណត់ទោសជាប់ពន្ធនាគារចន្លោះពី២០ ទៅ៣០ឆ្នាំដែរ នៅពេលប្រៀបធៀបនឹងទោសជាប់ពន្ធនាគារអស់មួយជីវិតក្នុងករណីដែលឧក្រិដ្ឋកម្មនេះប្រព្រឹត្តឡើងបានសម្រេច។ និយមន័យនៃអ្នកផ្តើមគំនិតនៅក្នុងមាត្រា២៨ នៃក្រមព្រហ្មទណ្ឌកម្ពុជាចែងយ៉ាងច្បាស់ថា អ្នកផ្តើមគំនិតអាចទទួលទោសតែក្នុងករណីណាដែលបទល្មើសត្រូវបានប្រព្រឹត្តឡើង ឬត្រូវបានប៉ុនប៉ងតែប៉ុណ្ណោះ។ ដូច្នេះ វាតម្រូវឲ្យមានអំពើ ឬការប៉ុនប៉ងណាមួយជាក់លាក់។ ការត្រឹមតែញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍មិនអាចស្ថិតនៅក្រោមទម្រង់នៃការទទួលខុសត្រូវមួយនេះឡើយ។ ទម្រង់នៃការទទួលខុសត្រូវទាំងនេះ ជាទូទៅ ស្រដៀងគ្នាទៅនឹងទម្រង់នៃការទទួលខុសត្រូវនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ទោះបីជាយ៉ាងនេះក្តី មានការកត់សម្គាល់ថា តុលាការព្រហ្មទណ្ឌកម្ពុជាពុំកំណត់ការញុះញង់ជាសាធារណឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ប្រល័យពូជសាសន៍ជាបទល្មើសព្រហ្មទណ្ឌជាក់លាក់នោះទេ។ ក៏ប៉ុន្តែ ទម្រង់នៃការទទួលខុសត្រូវ មួយនេះមានចែងនៅក្នុងមាត្រា៤៩៤ និងមាត្រា៤៩៦ នៃក្រមព្រហ្មទណ្ឌកម្ពុជា ដោយកំណត់ការញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និង/ឬ ឲ្យប្រព្រឹត្តការរើសអើងប្រឆាំងនឹងសមាជិកក្រុមនៃជាតិពិន្ទុ ជាតិសាសន៍ ពូជសាសន៍ ឬ សាសនាជាក់លាក់ណាមួយ ជាបទល្មើសព្រហ្មទណ្ឌ។ នៅក្នុងចំណុចនេះ ការញុះញង់ត្រូវបានកំណត់និយមន័យថាជា (១) សុន្ទរកថាណាមួយដែលធ្វើឡើងជាសាធារណៈ ឬនៅក្នុងពេលប្រជុំ (២) សំណេរ ឬ រូបភាពដែលត្រូវបានដាក់បង្ហាញ ឬ ចែកចាយជាសាធារណៈ និង (៣)

[55] មាត្រា ១៨៥ (បទត្រៀមរៀបចំក្នុងបទប្រល័យពូជសាសន៍) ចែងថា៖ "ការចូលរួមក្នុងក្រុមណាមួយដែលបង្កើតឡើង ឬ ចូលរួមក្នុងសន្និដ្ឋិភាពដែលធ្វើឡើងដើម្បីរៀបចំអំពើប្រល័យពូជសាសន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ទៅ ៣០ (សាមសិប) ឆ្នាំ"។

ដោយការផ្សព្វផ្សាយតាមរយៈសោតទស្សន៍ដល់សាធារណជន[56]។ ក្រៅពីបទឧក្រិដ្ឋខាងលើ ការញុះញង់ដោយរើងអើសប្រឆាំងនឹងបុគ្គលដែលមានអត្តសញ្ញាណជាជាតិពិន្ទុ ជាតិសាសន៍ ពូជសាសន៍ ឬសាសនា ត្រូវបានហាមឃាត់[57]។ ការញុះញង់គឺជាបទល្មើសមិនបានសម្រេចមួយអនុលោមតាមក្រមព្រហ្មទណ្ឌកម្ពុជា ពីព្រោះបទល្មើសនេះមានចែងយ៉ាងច្បាស់នៅក្នុងមាត្រា ៤៩៦ ថា ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាព[58] ។

មាត្រា៤៩៩ នៃក្រមព្រហ្មទណ្ឌកម្ពុជាក៏ចាប់បុគ្គលទាំងឡាយណាដែលចូលរួមនៅក្នុងសមាគមជនទុច្ចរិតឲ្យទទួលខុសត្រូវព្រហ្មទណ្ឌដែរ។ ទោះបីជាយ៉ាងនេះក្ដី ការទទួលខុសត្រូវបែបនេះត្រូវបានកំណត់គោលដៅតែទៅលើបទល្មើសសាមញ្ញតែប៉ុណ្ណោះ។ បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមពុំមានចែងនៅក្នុងបទបញ្ញត្តិនេះនៃក្រមព្រហ្មទណ្ឌកម្ពុជាឡើយ[59]។ ម្យ៉ាងវិញទៀត ក្រមព្រហ្មទណ្ឌកម្ពុជាពុំបានចងក្រងបញ្ចូលការទទួលខុសត្រូវព្រហ្មទណ្ឌរបស់មេយោធា ឬប្រធានក្នុងជួរស៊ីវិលឡើយ។ នៅក្នុងក្របខណ្ឌនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ទម្រង់នៃការទទួលខុសត្រូវនេះកំណត់អំពើអកម្មរបស់ថ្នាក់លើនៅពេលខកខានក្នុងការទប់ស្កាត់ ឬដាក់ទោសអំពើណាមួយនៃបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមដែលជាបទល្មើសព្រហ្មទណ្ឌ[60]។ ហេតុដូច្នេះយោងតាមច្បាប់កម្ពុជា ថ្នាក់លើមិនត្រូវបានចាប់ឲ្យទទួលខុសត្រូវនៅក្រោមទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើនោះទេ ទោះបីជាថ្នាក់លើរូបនោះខកខានក្នុងការទប់ស្កាត់ ឬដាក់ទណ្ឌកម្មលើបទល្មើស និងបានដឹងថា អំពើទាំងនោះនឹងត្រូវប្រព្រឹត្ត ឬបានប្រព្រឹត្តឡើងរួចហើយក្ដី។ អំពើអកម្មនេះអាចមានផលប៉ះពាល់ធំធេងលើការចោទប្រកាន់ចំពោះបទល្មើសអន្តរជាតិនៅក្នុងប្រទេសកម្ពុជា។ ការទទួលខុសត្រូវរបស់ថ្នាក់លើ ជាទូទៅ ត្រូវបានចាត់ទុកថាជាឧបករណ៍សំខាន់

---

56 មាត្រា៤៩៤ (លក្ខខណ្ឌអត្ថិភាពនៃការញុះញង់) ចែងថា៖ "ដើម្បីអនុវត្តផ្នែកនេះ ការញុះ ញង់អាចត្រូវផ្ដន្ទា ទោស កាលបើអំពើនេះត្រូវបានប្រព្រឹត្ត៖ (១) ដោយសំដីតាមប្រភេទណាក៏ដោយ ដែលប្រកាស នៅក្នុងទីកន្លែងសាធារណៈ ឬ នៅក្នុងពេល ប្រជុំជាសាធារណៈ។ (២) ដោយសំណេរ ឬ គំនូរ តាមប្រភេទណាក៏ដោយ ដែលត្រូវផ្សព្វផ្សាយនៅក្នុងចំណោម សាធារណជន ឬ តាំង ឲ្យសាធារណជនមើល។ (៣) ដោយគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន"។

57 មាត្រា៤៩៦ (បទញុះញង់ឲ្យមានការរើសអើង) ចែងថា៖ "អំពើញុះញង់ដោយផ្ទាល់តាមមធ្យោបាយណាមួយ ដែលមានចែងក្នុងមាត្រា ៤៩៤ (លក្ខខណ្ឌអត្ថិភាពនៃការញុះញង់) នៃក្រមនេះ ឲ្យប្រព្រឹត្តការរើសអើង ការគុំគួន ឬហិង្សា ចំពោះបុគ្គលណាម្នាក់ ឬ ក្រុមណាមួយ ដោយមូលហេតុបុគ្គលនេះជាសមាជិកជាកំណត់នោះ ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី១ (មួយ) ឆ្នាំទៅ៣ (បី) ឆ្នាំ និង ពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាពទេ"។

58 *ដូចខាងលើ*។

59 មាត្រា៤៩៩ (បទចូលរួមសមាគមនៃជនទុច្ចរិត) ចែងថា៖ "ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ការចូលរួមក្នុងក្រុម ឬសន្និដ្ឋិភាពដែលត្រូវបង្កើតឡើងដើម្បី៖ (១) ប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ឬច្រើន ប្រឆាំងនឹងបុគ្គល ដែលមានចែងនៅក្នុងជំពូកទី១ ស្ដីពីការប៉ះពាល់ដល់ជីវិតមនុស្ស ដល់ជំពូកទី ៦ ស្ដីពីការប៉ះពាល់ដល់បុគ្គលភាព ក្នុងមាតិកាទី ២ ស្ដីពីការប៉ះពាល់ដល់មនុស្សនៃគន្ថីទី២ ស្ដីពីបទល្មើសប្រឆាំងនឹងបុគ្គលនៃក្រមនេះ។ (២) ប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ឬ ច្រើន ប្រឆាំងនឹង ទ្រព្យសម្បត្តិ ដែលមាន ចែងនៅក្នុងគន្ថីទី៣ ស្ដីពីបទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិនៃក្រមនេះ។ បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមមានចែងនៅក្នុងគន្ថីទី២ មាតិកាទី ១។

60 សូមមើល មាត្រា ២៨ នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

មួយក្នុងការចោទប្រកាន់ឲ្យបានត្រឹមត្រូវលើអំពើឃោរឃៅធំៗ ដោយសារអំពើទាំងនេះ ជាទូទៅត្រូវបានប្រព្រឹត្តឡើងដោយមានការជួយជ្រោមជ្រែងពីរចនាសម្ព័ន្ធឋានានុក្រមចាត់តាំង[61] ។

ចំពោះទម្រង់នៃការការពារខ្លួនវិញ ក្រមព្រហ្មទណ្ឌកម្ពុជាបញ្ញត្តិអំពីទម្រង់ការពារខ្លួន ដែលត្រូវបានទទួលស្គាល់ជាទូទៅ ពោលគឺ បញ្ហាវិបល្លាសស្មារតី (មាត្រា៣១) ការការពារស្របច្បាប់ (មាត្រា៣៣) និងស្ថានភាពចាំបាច់ (មាត្រា៣៥)។ ស្ថានភាពដែលទម្រង់ការពារបែបនេះត្រូវបានយកមកអនុវត្តនោះ គឺមានលក្ខណៈស្រដៀងគ្នានឹងទម្រង់ការពារនានា ដូចមានចែងនៅក្នុងមាត្រា ៣១ នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ។ នៅក្នុងករណីខ្លះ ច្បាប់កម្ពុជាមានលក្ខណៈតឹងរ៉ឹងជាងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយសារសារជាតិស្រវឹង សារជាតិញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ មិនអាចយកមកអះអាងដើម្បីធ្វើជាការការពារខ្លួនបានឡើយ[62]។ មាត្រា៣២ នៃក្រមព្រហ្មទណ្ឌកម្ពុជាចែងអំពីការការពារកើតចេញពីបញ្ជារបស់ថ្នាក់លើ ឬអំពើដែលត្រូវបានប្រព្រឹត្តឡើងទៅតាមអំណាច ឬបញ្ជាស្របច្បាប់។ ទោះបីជាយ៉ាងនេះក្តី បទបញ្ញត្តិនេះមិនអាចយកមកអនុវត្តចំពោះបទល្មើសសាមញ្ញ ពីព្រោះថាវាក្យខណ្ឌចុងក្រោយនៅក្នុងមាត្រា៣២ នៃក្រមព្រហ្មទណ្ឌកម្ពុជាចែងយ៉ាងច្បាស់ថា គ្មានការការពារកើតចេញពីបញ្ជាថ្នាក់លើ ឬ "បញ្ជារបស់អាជ្ញាធរស្របច្បាប់" ចំពោះអំពើនៃបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមនោះឡើយ[63]។

## IV. អភ័យឯកសិទ្ធិ និងការរារាំងពីការចោទប្រកាន់ផ្សេងទៀត

ប្រទេសកម្ពុជាជាប្រទេសរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ហើយព្រះមហាក្សត្រដែលគ្រងរាជទទួលបាននូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ។ អនុលោមតាមមាត្រា៧ នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា "អង្គព្រះមហាក្សត្រមិនអាចនរណារំលោភបំពានបានឡើយ"។ លើសពីនេះ រដ្ឋធម្មនុញ្ញបានផ្តល់អភ័យឯកសិទ្ធិជូនដល់សមាជិកសភា (មាត្រា៨០)[64] និងសមាជិកព្រឹទ្ធសភា

---

[61] សូមមើល Gerhard WERLE, *Principles of International Criminal Law* (Leiden: TMC Asser Press, 2005) កថាខណ្ឌ ៣៧០។

[62] មាត្រា ៣១(៣) (ការមិនទទួលខុសត្រូវព្រហ្មទណ្ឌដោយសារមូលហេតុវិបល្លាស្មារតី) ចែងថា៖ "កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើសនៅពេលដែលជននោះកើតវិបល្លាសស្មារតី ដោយសារ ការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិ ដែលច្បាប់ហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ"។

[63] មាត្រា ៣២ នៃក្រមព្រហ្មទណ្ឌកម្ពុជា (ការអនុញ្ញាតដោយច្បាប់ ឬ អាជ្ញាធ រ) ចែងថា៖ "ចារី សហចារី អ្នកផ្តើម គំនិត ឬ សម គំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋ ប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាច លើកលែងឲ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួន ទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ៖ (១)ជនល្មើសនោះបានប្រព្រឹត្តអំពើដែលបញ្ញត្តិអនុញ្ញាត ឬ មិនហាមឃាត់ដោយច្បាប់ជាធរមាន។ (២) បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់"។

[64] មាត្រា៨០ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា៖ "តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា។ តំណាងរាស្ត្រូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុ ពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន សមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះ សម័យប្រជុំនៃរដ្ឋសភា វៀរលែង តែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ច ត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូន គណៈកម្មាធិការអចិន្ត្រៃយ៍

(មាត្រា១០៤ថ្មី)[65]។ ក៏ប៉ុន្តែ សមាជិករាជរដ្ឋាភិបាលពុំទទួលបានអភ័យឯកសិទ្ធិ*តាមផ្លូវច្បាប់* នោះទេ។ នៅក្នុងការអនុវត្តយុត្តាធិការរបស់ខ្លួន តុលាការព្រហ្មទណ្ឌអន្តរជាតិ អនុលោមតាមមាត្រា ២៧ នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ មិនខ្វល់នឹងមុខតំណែងផ្លូវការណាមួយនោះទេ ដរាបណាតុលាការមានយុត្តាធិការទទួលខុសត្រូវលើបទឧក្រិដ្ឋនៅក្រោមអំណាចរបស់ខ្លួន។ ក៏ប៉ុន្តែ ការមិនមានបទបញ្ញត្តិចែងថា អភ័យឯកសិទ្ធិពុំអនុវត្តចំពោះបទល្មើសអន្តរជាតិ អាចរារាំងការចោទប្រកាន់នៅថ្នាក់ជាតិ និងកិច្ចសហប្រតិបត្តិការណ៍ជាមួយនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ដោយសារហេតុផលនេះ ក្រមព្រហ្មទណ្ឌកម្ពុជាពុំអាចគោរពឲ្យបានពេញលេញចំពោះគោលការណ៍នៃយន្តការបំពេញបន្ថែមបាននៅឡើយ។

លក្ខន្តិកទីក្រុងរ៉ូមពុំហាមឃាត់ចំពោះការលើកលែងទោសជាទូទៅចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមនោះទេ។ ក៏ប៉ុន្តែមានការយល់ស្របគ្នាជាឯកច្ឆ័ន្ទថា ការរារាំងពីការចោទប្រកាន់បែបនេះ គឺផ្ទុយនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយវាបន្ថយអានុភាពលើស្មារតីនៃលក្ខន្តិកទីក្រុងរ៉ូម[66]។ ក្រមព្រហ្មទណ្ឌកម្ពុជាចែងអំពីលទ្ធភាពនៃការលើកលែងទោសជាទូទៅនៅក្នុងមាត្រា ៩០ថ្មី(ពីរ)(៤)នៃរដ្ឋធម្មនុញ្ញកម្ពុជា និងមាត្រា១៤៩នៃក្រមព្រហ្មទណ្ឌកម្ពុជា[67] និងការលើកលែងទោសអនុលោមតាមមាត្រា២៧នៃ

របស់រដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច។ សេចក្តីសម្រេច របស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យ ប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័ត តាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល។ ក្នុង ករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឲ្យផ្អាក តាមមតិភាគច្រើនបីភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល”។

[65] មាត្រា១០៤ថ្មី នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា៖ “សមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធភាព។ សមាជិកព្រឹទ្ធសភារូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។ ការចោទ ប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន សមាជិកណាមួយនៃព្រឹទ្ធសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីព្រឹទ្ធសភា ឬពី គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ក្នុងចន្លោះ សម័យប្រជុំនៃព្រឹទ្ធសភា វៀរលែង តែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ច ត្រូវធ្វើសេចក្តីរាយការណ៍ជូនព្រឹទ្ធសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាជាបន្ទាន់ដើម្បីសម្រេច។ សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ ដើម្បីអនុម័ត តាមមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល។ ក្នុង ករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់ សមាជិកព្រឹទ្ធសភាណាមួយត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបានបញ្ចេញមតិឲ្យផ្អាក តាមមតិភាគច្រើនបីភាគបួននៃសមាជិកព្រឹទ្ធសភាទាំងមូល”។

[66] Gerhard WERLE, លេខយោងជើងទំព័រ ៦១ *ដូចខាងលើ* កថាខណ្ឌ ១៨៩។ Antonio CASSESE, *International Criminal Law* (Oxford: Oxford University Press, 2003) ត្រង់ទំព័រ ៣១៥។

[67] មាត្រា ១៤៩ (អានុភាពនៃការលើកលែងទោសជាទូទៅ) ចែងថា៖ “ការលើកលែងទោសជាទូទៅដូចមានចែងក្នុងមាត្រា ៩០ ថ្មី (ពីរ) វាក្យខណ្ឌទី ៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លុបបំបាត់ ចោលនូវទណ្ឌកម្មដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីការលើកលែងទោសជាទូទៅ។ ទោសមិន អាចយកមកអនុវត្តទេ។ ទោស ដែលកំពុងអនុវត្តត្រូវបានបញ្ចប់។ ប៉ុន្តែ ចំពោះប្រាក់ពិន័យ និងប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ មិនអាចទារសំណងពីរដ្ឋវិញបានទេ”។

រដ្ឋធម្មនុញ្ញកម្ពុជា និងមាត្រា១៩៧នៃក្រមព្រហ្មទណ្ឌកម្ពុជា[68]។ ការលើកលែងទោសអនុវត្តតែចំពោះទោសដែលកំពុងអនុវត្តក្រោយពេលមានសាលក្រម ឬសាលដីកាស្ថាពរពីតុលាការតែប៉ុណ្ណោះ[69]។ ដោយហេតុថា ពាក្យពេចន៍នៅក្នុងមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌកម្ពុជាផ្ទុយនឹងមាត្រា៩០ នៃរដ្ឋធម្មនុញ្ញកម្ពុជា។ មាត្រា៩០នេះ ចែងថា ការលើកលែងទោសជាទូទៅដែលផ្តល់ជូនដោយសភាមានអានុភាពបញ្ឈប់ការចោទប្រកាន់ ដូច្នេះ វាផ្តល់នូវអភ័យឯកសិទ្ធិពីការចោទប្រកាន់ដោយប្រសិទ្ធភាព[70]។ ទោះក្នុងករណីណាក៏ដោយ មាត្រា១៩៨ និងមាត្រា១៥១នៃក្រមព្រហ្មទណ្ឌកម្ពុជាចែងថា លើកលែងតែច្បាប់ ឬព្រះរាជក្រឹត្យចែងផ្ទុយពីនេះតែប៉ុណ្ណោះ ទើបការលើកលែងទោសជាទូទៅ ឬការលើកលែងទោស ពុំត្រូវរារាំងដល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានសំណងចំពោះព្យសនកម្មដែលបានកើតឡើងនោះទេ។

ការលើកលែងទោសជាទូទៅ និងការលើកលែងទោសចំពោះអំពើសម្លាប់រង្គាលពុំមែនជាទស្សនទានបរទេសដែលត្រូវបានយកមកដាក់បញ្ចូលនៅក្នុងនយោបាយកម្ពុជានោះទេ។ នៅក្នុងឆ្នាំ១៩៩៦ សម្តេចព្រះបាទនរោត្តម សីហនុ បានចេញព្រះរាជក្រឹត្យលើកលែងទោស អៀង សារី ចំពោះទោសដែលត្រូវបានសម្រេចនៅចំពោះមុខតុលាការប្រជាជនបដិវត្តន៍ និងការលើកលែងទោសជាទូទៅក្រោមច្បាប់ឆ្នាំ ១៩៩៤ ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់។ ក្រោយពីចេញព្រះរាជក្រឹត្យនេះរួច អៀង សារី និងខ្មែរក្រហមដែលនៅសេសសល់ប្រមាណ ១០០០នាក់ បានផ្តាច់ខ្លួនចុះចូល និងបានឈានទៅដល់ការបិទបញ្ចប់ជម្លោះដែលកើតមាននៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំកន្លងទៅ។

អ.វ.ត.ក ចោទប្រកាន់ អៀង សារី ថាជាជនម្នាក់ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្រោមរបបខ្មែរក្រហមក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ និងបានច្រានចោលការអះអាងថា អនុលោមតាមព្រះរាជក្រឹត្យ និងច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ អៀង សារី មិនអាចត្រូវបានចោទប្រកាន់នៅចំពោះមុខតុលាការ*ពិសេស*នេះទេ។ អ.វ.ត.ក បានសម្រេចថា វិសាលភាពនៃព្រះរាជក្រឹត្យ និងច្បាប់លើកលែងទោសជាទូទៅពុំបានដាក់បញ្ចូលបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ទារុណកម្ម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ នោះទេ[71]។ អ.វ.ត.ក

[68] មាត្រា១៩៧ (អានុភាពនៃការអនុគ្រោះទោស) ចែងថា៖ "ការអនុគ្រោះទោសដោយការបន្ធូរបន្ថយទោស ឬការ លើកលែងទោសដោយអនុលោមតាមមាត្រា២៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លើកលែងឲ្យ ទណ្ឌិតរួចផុតពីការអនុវត្តទោសដែលអនុគ្រោះនោះ"។

[69] អ.វ.ត.ក *នួន ជា អៀង សារី អៀង ធីរិទ្ធ ខៀវ សំផន* សំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ សេចក្តី សម្រេចលើអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ កថាខណ្ឌ២៥។

[70] សូមមើលផងដែរ *ដូចខាងលើ* កថាខណ្ឌ២៦។

[71] *ដូចខាងលើ* កថាខណ្ឌ ៥៥។

បានផ្តល់ហេតុផលថា "ទោះបីជាច្បាប់ស្តីពីការលើកលែងទោសជាទូទៅធ្វើឡើងនៅក្នុងឆ្នាំ១៩៩៦ អាចជាឧបករណ៍ចរចាមួយដ៏មានប្រយោជន៍នៅក្នុងការបញ្ចប់ជម្លោះក៏ដោយ ក៏អង្គជំនុំជម្រះវិសាមញ្ញកត់សម្គាល់ឃើញថា ច្បាប់នេះពុំបានអមមកជាមួយនូវការពិត ឬដំណើរការផ្សះផ្សាឡើយ។ មានតែ ការពិត និងដំណើរការ ផ្សះផ្សាជាតិតែប៉ុណ្ណោះទើបអាចលាតត្រដាងព័ត៌មានពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែលចោទប្រកាន់លើជនជាប់ចោទ អៀង សារី ឬអាចទទួលស្គាល់ជាអន្តរជាតិលើសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានដំណោះស្រាយដោយមានប្រសិទ្ធភាព"[72]។ អ.វ.ត.ក គឺជាតុលាការកម្ពុជាមួយ ហើយយុត្តិសាស្ត្ររបស់តុលាការនេះ យ៉ាងហោចណាស់ គឺជាឬគួរតែយកមកធ្វើជាគោលការណ៍ណែនាំនៅក្នុងប្រទេសកម្ពុជា[73]។ នៅក្នុងករណីណាក៏ដោយ សេចក្តីសម្រេចនេះហាក់ដូចជាស្របតាមវិធីសាស្ត្រជាទូទៅនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនានា[74] និងតុលាការសិទ្ធិមនុស្ស[75] ដែលការលើកលែងទោសជាទូទៅត្រូវបានចាត់ទុកជាមោឃៈចំពោះបទល្មើសអន្តរជាតិ។ ពាក់ព័ន្ធនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា២១(១)(ខ) និង(៣) នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលចែងថា "តុលាការត្រូវអនុវត្ត[...] ក្នុងករណីសមស្របនឹងសន្ធិសញ្ញា និងគោលការណ៍ ព្រមទាំងវិធាននៃច្បាប់អន្តរជាតិដែលនៅជាធរមាន" ហើយ "ការអនុវត្ត និងការបកស្រាយច្បាប់ អនុលោមតាមមាត្រានេះត្រូវឲ្យស្របជាមួយនឹងសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិ" ការរារាំងតុលាការព្រហ្មទណ្ឌអន្តរជាតិមិនឲ្យទទួលស្គាល់ច្បាប់ស្តីពីការលើកលែងទោសជាទូទៅចំពោះបទឧក្រិដ្ឋនៅក្រោមយុត្តាធិការ

---

[72] *ដូចខាងលើ* កថាខណ្ឌ ៥៤។

[73] អង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក បានរៀបរាប់ អំពីលក្ខណៈនៃ អ.វ.ត.ក តាមពាក្យពេចន៍ ដូចតទៅនេះ៖ "តុលាការ[មួយ]ដែលមានលក្ខណៈពិសេស និង ឯករាជ្យនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា [...] បង្កើតឡើងដើម្បីឲ្យដំណើរការដាច់ដោយឡែកពីប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ និងដើម្បីសម្រេចសេចក្តីលើតែក្រុមជនជាប់ចោទដែលត្រូវបានកំណត់និយមន័យយ៉ាងចង្អៀត ពីបទឧក្រិដ្ឋជាក់លាក់ដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលកំណត់មួយ"។ សូមមើល អ .វ.ត.ក *កាំង ហ្គេកអ៊ាវ* អង្គជំនុំជម្រះសាលាដំបូង *សេចក្តីសម្រេចលើសំណើសុំដោះលែងឲ្យមានសេរីភាព* សំណុំរឿង ០០១/១៨-៧-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ (ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០០៩) កថាខណ្ឌ ១០។

[74] តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Anto FURUNDZIJA* សំណុំរឿង IT-95-17/1-T សាលក្រម ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨ កថាខណ្ឌ ១៥៥។ តុលាការ SCSL រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Morris KALLON និង Brima KAMARA* សំណុំរឿង SCSL-2004-15-AR72(E) និង SCSL-2004-16-AR72(E), សេចក្តីសម្រេចលើការជំទាស់តវ៉ាប្រឆាំងនឹងយុត្តាធិការ៖ Lomé Accord Amnesty ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៤ កថាខណ្ឌ ៦៦-៧៤។ *សូមមើលផងដែរ* តុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Radovan KARADŽIĆ* រឿងក្តី IT-95-5/18-AR73.4 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ Karadžić ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើកិច្ចព្រមព្រៀង Holbrooke Agreement ដែលត្រូវបានចោទប្រកាន់ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩ កថាខណ្ឌ ៥២ ដែលលើកឡើងថា "បុគ្គលដែលត្រូវបានចោទប្រកាន់អំពីបទឧក្រិដ្ឋពុំអាចមានការរំពឹងទុកស្របច្បាប់ថានឹងរួចផុតពីការចោទប្រកាន់បាននោះទេ"។

[75] ឯកសារ អ.ស.ប U.N. Doc. HRI\GEN\1\Rev.1 at 30 (1994), គណៈកម្មាធិការសិទ្ធិមនុស្ស (សម័យប្រជុំលើកទី ៤៤ ឆ្នាំ ១៩៩២) មតិយោបល់ទូទៅលេខ ២០ មាត្រា ៧ កម្រងមតិ និងអនុសាសន៍ទូទៅដែលអនុម័តដោយស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស កថាខណ្ឌ ១៥ (ពាក់ព័ន្ធនឹងបទធ្វើទារុណកម្ម)។ តុលាការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិក រឿងក្តី *Chumbipuma Aguirre* និងជនផ្សេងទៀត ទល់នឹង ប្រទេសប៉េរ៉ូ *(*រឿងក្តី *Barrios Altos)* សាលក្រម ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០១ កថាខណ្ឌ ៤១ ៤៤។

របស់តុលាការនេះ ដោយសារការលើកលែងទោសជាទូទៅនឹងធ្វើឲ្យការអនុវត្តមួយនេះនឹងផ្ទុយពីបទដ្ឋានស្តីពីសិទ្ធិមនុស្ស និងសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានដំណោះស្រាយដោយប្រសិទ្ធភាពចំពោះការរំលោភសិទ្ធិមនុស្ស[76]។ ជាលទ្ធផល ការខកខានក្នុងការដកចេញការលើកលែងទោសជាទូទៅ និងការលើកលែងទោសចំពោះបទឧក្រិដ្ឋអន្តរជាតិ ប្រសិនបើផ្តល់ឲ្យមែននោះ វានឹងធ្វើឲ្យប៉ះពាល់ដល់គោលការណ៍នៃយន្តការបំពេញបន្ថែម។

អាជ្ញាយុកាលសម្រាប់បទល្មើសមានចែងនៅក្នុងមាត្រា១៩២ ដល់មាត្រា១៩៦ នៃក្រមព្រហ្មទណ្ឌកម្ពុជា។ គ្មានអាជ្ញាយុកាលណាមួយចែងកំណត់សម្រាប់បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋសង្គ្រាម និងបទឧក្រិដ្ឋសង្គ្រាមនោះទេ។ មាត្រា ១៩៣ នៃក្រមព្រហ្មទណ្ឌកម្ពុជាបញ្ញត្តិថា បទឧក្រិដ្ឋ បែបនេះពុំមានអាជ្ញាយុកាលនោះទេ[77]។ មាត្រា៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាក៏បានកំណត់ដូចគ្នានេះដែល[78]។ គួរកត់សម្គាល់ត្រង់ចំណុចនេះថា ដោយសារប្រទេសកម្ពុជា មកទល់ពេលនេះ នៅពុំទាន់ផ្តល់ សច្ចាប័នលើអនុសញ្ញានៃអង្គការសហប្រជាជាតិឆ្នាំ១៩៦៨ ស្តីពីការមិនអាចអនុវត្តទៅបាននៃអាជ្ញាយុកាលលើបទឧក្រិដ្ឋសង្គ្រាម និងបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ។ នៅក្នុងករណីណាក៏ដោយ មាត្រា១៩៣ នៃក្រមព្រហ្មទណ្ឌកម្ពុជាស្របតាមមាត្រា២៩ នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលចែងថា "បទឧក្រិដ្ឋនៅក្នុងយុត្តាធិការតុលាការពុំមានអាជ្ញាយុកាលកំណត់ឡើយ"។

## V. បញ្ហានៃយន្តការបំពេញបន្ថែម

វិសមភាព ឬភាពផ្ទុយគ្នារវាងបទបញ្ញត្តិស្តីពីបទល្មើសនៃបទឧក្រិដ្ឋសង្គ្រាមមួយចំនួន និងការពុំមានបទបញ្ញត្តិចែងអំពីបទល្មើសភាគច្រើននៃបទឧក្រិដ្ឋសង្គ្រាម ដូចដែលមានចែងនៅក្នុងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិអាចមានផលប៉ះពាល់លើលក្ខខណ្ឌនៃយន្តការបំពេញបន្ថែម ដូចមានចែងនៅក្នុងមាត្រា១៧(៣) នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ដូច្នេះ វាមានសារៈសំខាន់ក្នុងការបែងចែករវាងវិសមភាព ឬភាពផ្ទុយគ្នានៅក្នុងនិយមន័យនៃបទល្មើសក្នុងមាត្រា ១៩៣ និងមាត្រា១៩៤ នៃក្រមព្រហ្មទណ្ឌកម្ពុជា ជាមួយនឹងការពុំកំណត់បទល្មើសខ្លះថាជាបទល្មើសព្រហ្មទណ្ឌ។

---

[76] សូមមើលជាទូទៅ Christine van den WYNGAERT and Tom ONGENA, *Ne bis in idem* Principle, Including the Issue of Amnesty, in Antonio CASSESE, Paola GAETA, and John JONES, *The Rome Statute of the International Criminal Law: A Commentary* (Oxford: Oxford University Press, 2002), 724-726។

[77] មាត្រា១៩៣ (ភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋមួយចំនួន) ចែងថា៖ "ទោសដែលប្រកាសពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម មិនអាចផុតរលត់អាជ្ញាយុកាលទេ"។ ទោះបីជាមានបទបញ្ញត្តិនេះចែងក៏ដោយ ប្រទេសកម្ពុជាពុំទាន់ផ្តល់សច្ចាប័នលើអនុសញ្ញាឆ្នាំ១៩៦៨ នៃ អ.ស.ប ស្តីពីភាពមិនអាចផុតរលត់អាជ្ញាយុកាលចំពោះបទឧក្រិដ្ឋសង្គ្រាម និងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ)។

[78] មាត្រា៩ (ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់)៖ "បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និង បទឧក្រិដ្ឋសង្គ្រាម មិនអាចផុតអាជ្ញាយុកាលបានទេ"។

ពាក់ព័ន្ធនឹងវិសមភាពនៃបទបញ្ញត្តិមួយចំនួនដូចបានគូសបញ្ជាក់ខាងលើ វាមានសារៈសំខាន់ក្នុងការបែងចែកនិយមន័យទូលាយ ជាមួយនឹងនិយមន័យចង្អៀតនៅពេលប្រៀបធៀបនិយមន័យទាំងពីរទៅនឹងលក្ខន្តិកទីក្រុងរ៉ូម។ និយមន័យទូលាយដូចបានបង្ហាញនៅខាងលើពុំបានបង្កើតជាការលំបាកណាមួយចំពោះគោលការណ៍នៃយន្តការបំពេញបន្ថែមនោះឡើយ ពីព្រោះនិយមន័យទាំងនេះ អាចគ្របដណ្តប់រួមនូវនិយមន័យនៅក្នុងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ។ និយមន័យចង្អៀតបានបង្កនូវការលំបាកជាច្រើន ជាពិសេស ប្រសិនបើអំពើណាមួយស្ថិតនៅក្រៅវិសាលភាពនៃនិយមន័យក្នុងច្បាប់កម្ពុជា ប៉ុន្តែអំពើនោះជាបទល្មើសមួយប្រភេទដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ដូចបានពន្យល់ខាងលើ ករណីនេះកើតឡើងចំពោះបទឧក្រិដ្ឋប្រឆាំងនឹងបុគ្គលដែលត្រូវបានការពារក្រៅពីជនស៊ីវិល ពីព្រោះច្បាប់ព្រហ្មទណ្ឌកម្ពុជាពុំបានការពារជាក់លាក់ដល់ប្រភេទបុគ្គលជាក់លាក់ដូច្នេះទេ។ នៅក្នុងស៊ីនណារីយ៉ូបែបនេះ និងប្រសិនបើអំពើល្មើសណាមួយមិនអាចចោទប្រកាន់ជាបទល្មើសសាមញ្ញ មានន័យថា ប្រទេសកម្ពុជាមិនអាចចោទប្រកាន់ឲ្យមានប្រសិទ្ធភាពបាននោះទេ។

នៅក្នុងករណីដែលច្បាប់កម្ពុជាពុំបានកំណត់បទល្មើសនៃបទឧក្រិដ្ឋសង្គ្រាមដែលមានចែងនៅក្នុងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ ចាំបាច់ត្រូវពិចារណាដូចខាងក្រោមនេះ។ ជាទូទៅក្នុងករណីច្បាប់ព្រហ្មទណ្ឌកម្ពុជាពុំមានចែង សេណារីយ៉ូស្តីពីការពុំមានលទ្ធភាពនឹងលេចឡើងយោងតាមមាត្រា ១៧(៣)នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ដូចបានបង្ហាញខាងលើ ក្រមព្រហ្មទណ្ឌកម្ពុជាបានបញ្ញត្តិបទល្មើសព្រហ្មទណ្ឌខ្លះនៃបទឧក្រិដ្ឋសង្គ្រាមនៅក្នុងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិមកដាក់បញ្ចូលជាបទល្មើសព្រហ្មទណ្ឌរបស់ខ្លួន។ ទោះបីជាយ៉ាងនេះក្តី អាចមានទឡ្ហីករណ៍ដែលលើកឡើងថា មាត្រា៨ នៃក្រមព្រហ្មទណ្ឌកម្ពុជាអនុញ្ញាតឲ្យមានការបកស្រាយគាំទ្រដល់ការបើកការចោទប្រកាន់បទល្មើសក្រោមច្បាប់មនុស្សធម៌អន្តរជាតិ និងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ។ មាត្រានេះលើកឡើងថា "បទបញ្ញត្តិនៃក្រមនេះនឹងពុំអាចនាំឲ្យមានការបង្កើតស្ថានភាពយុត្តិនិសេធចំពោះជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរ ដែលកំណត់ដោយច្បាប់ដោយឡែកទាក់ទងដល់ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬអនុសញ្ញាអន្តរជាតិ ដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជាឡើយ"។ ក៏ប៉ុន្តែ នៅសល់បញ្ហាមួយពាក់ព័ន្ធនឹងការបកស្រាយមាត្រានេះ និងបញ្ហានៃការគោរពតាមគោលការណ៍នីត្យានុកូលភាព (*គ្មានបទល្មើស ប្រសិនបើគ្មានច្បាប់ចែង*) ដែលបានចែងនៅក្នុងមាត្រា៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា.[79] *ច្បាប់តឹងរឹង* និងអនុសញ្ញាសិទ្ធិមនុស្សអន្តរជាតិផ្សេងទៀតដែលប្រទេសកម្ពុជាជារដ្ឋ

[79] សូមមើល លេខយោងជើងទំព័រ ៤ *ដូចខាងលើ*។

ភាគី[80]។ ផ្ទុយមកវិញ បទបញ្ញត្តិនេះអាចយល់ថាជាការអនុញ្ញាតឲ្យស្ថាប័នតុលាការកម្ពុជាបកស្រាយបទបញ្ញត្តិជាក់លាក់នៅក្នុងមាត្រា១៩៣ និងមាត្រា១៩៤ នៃក្រមព្រហ្មទណ្ឌកម្ពុជាឲ្យស្របតាមរដ្ឋភាគីអន្តរជាតិផ្សេងទៀត។ ទោះបីជាយ៉ាងនេះក្តី មាត្រា៨ មិនអាចបកស្រាយថាជាការអនុញ្ញាតឲ្យកំណត់ជាបទល្មើសព្រហ្មទណ្ឌចំពោះអំពើបន្ថែមណាមួយ ដែលពុំត្រូវបានកំណត់នៅក្រោមច្បាប់កម្ពុជានោះទេ។ លើសពីនេះ មាត្រា៣១នៃរដ្ឋធម្មនុញ្ញកម្ពុជាត្រូវយកមកពិចារណា។ មាត្រា៣១ វាក្យខណ្ឌ១ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា៖

*ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។*

នៅក្នុងសេចក្តីសម្រេចដ៏ចម្រូងចម្រាស និងស្រពិចស្រពិលរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលជាស្ថាប័នតុលាការជាន់ខ្ពស់ជាងគេនៅក្នុងប្រទេសកម្ពុជា ត្រង់មាត្រា៣១ ទំនងជាត្រូវបានបកស្រាយដោយចៅក្រមនៅក្នុងក្រុមប្រឹក្សានេះថា មាត្រានេះចែងអំពីវិធីសាស្រ្តឯកនិយមពាក់ព័ន្ធនឹងការអនុវត្តសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិដែលត្រូវបានផ្តល់ សច្ចាប័នដោយព្រះរាជាណាចក្រកម្ពុជា។ សេចក្តីសម្រេចនេះបានលើកឡើងអំពីអនុសញ្ញាស្តីពីសិទ្ធិកុមារ និងបញ្ហាចោទថាតើច្បាប់កម្ពុជា ពោលគឺ មាត្រា៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលដកលទ្ធភាពចៅក្រមមិនគិតពីស្ថានត្រាប្រណីទោសដើម្បីបន្ថយ ឬព្យួរទោសនៅក្នុងករណីពាក់ព័ន្ធនឹងបទឧក្រិដ្ឋ គឺវាមានវិសមិតភាពជាមួយនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេស មាត្រា៣៧(ខ)។ ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចថា៖

*យល់ឃើញថា ជាគោលការណ៍ ក្នុងការជំនុំជម្រះក្តី ចៅក្រមពុំមែនគ្រាន់តែផ្អែកទៅលើមាត្រា៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋតែមួយនេះទេដើម្បីផ្តន្ទាទោសលើឧក្រិដ្ឋជន ប៉ុន្តែចៅក្រមត្រូវផ្អែកលើច្បាប់។ ពាក្យថាច្បាប់ខាងលើនេះមានន័យថា ច្បាប់ជាតិ រួមមាន រដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល ច្បាប់ទាំងឡាយដែលនៅជាធរមាន ហើយនឹងច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់រួចមកហើយ ជាពិសេស អនុសញ្ញាស្តីពីសិទ្ធិកុមារ[81]។*

---

[80] ឧទាហរណ៍ មាត្រា១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ ១៩៩២ សូមមើលគេហទំព័រ http://treaties.un.org/pages/ViewDetails.aspx?src=TREATY&mtdsg_no=IV-4&chapter=4&lang=en។

[81] ក្រុមប្រឹក្សាធម្មនុញ្ញ សំណុំរឿងលេខ ១៣១/០០៣/២០០៧ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០០៧ សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០០៧ អាចពិនិត្យមើលតាមរយៈគេហទំព័រ www.ccc.gov.kh/english/dec/2007/dec_003.html (បើកអានចុងក្រោយនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២)។

ការប្រកាសថា ពាក្យថា ច្បាប់ ក៏សំដៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន អាចបង្កើតជាបញ្ហាចោទថាតើប្រព័ន្ធឯកនិយម ឬទ្វិកនិយម អនុវត្តនៅក្នុងប្រទេសកម្ពុជា។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនឹងទំនងជាគាំទ្រលើប្រព័ន្ធឯកនិយម។ ផ្អែកតាមសេចក្តីសម្រេចនេះ លក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិពុំតម្រូវឲ្យចែងបញ្ចូលបទល្មើសនោះទេ ដោយសារប្រទេសកម្ពុជាបានផ្តល់ សច្ចាប័នលើលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិនៅថ្ងៃទី៧ ខែមករា ឆ្នាំ២០០២ រួចមកហើយ។ ការសម្រេចដូច្នេះគឺជាការផ្តល់យុត្តាធិការឲ្យប្រទេសកម្ពុជាលើគ្រប់បទល្មើសទាំងអស់ដែលមានចែងនៅក្នុងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ ទោះបីជាបទល្មើសទាំងអស់ពុំត្រូវបានចែងបញ្ចូលនៅក្នុងច្បាប់ជាតិក៏ដោយ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញនៅក្នុងរឿងក្តីខាងលើនេះបានបកស្រាយរដ្ឋធម្មនុញ្ញ ដោយផ្តល់ប្រយោជន៍ដល់ជនជាប់ចោទដែលជាអនីតិជន សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងសិទ្ធិមនុស្សជារួម។ម្យ៉ាងវិញទៀត អនុសញ្ញាស្តីពីសិទ្ធិកុមារគឺជាអនុសញ្ញាមួយដែលមានចង្អុលយោងយ៉ាងជាក់លាក់ត្រង់ពីរកន្លែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា។ ហេតុដូច្នេះ ទោះបីជាពាក្យពេចន៍មានលក្ខណៈស្រពិចស្រពិលក៏ដោយ ក៏វាអាចមានវិវាទថាតើសេចក្តីសម្រេចនេះគឺជាការច្រានចោលប្រព័ន្ធទ្វិកនិយម ឬថាតើសេចក្តីសម្រេចនឹងនៅតែជាករណីលើកលែងមួយតែប៉ុណ្ណោះ[82]។ ទោះក្នុងករណីណាក៏ដោយ និងដោយហេតុថាលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ កំណត់បទល្មើសព្រហ្មទណ្ឌចំពោះអំពើនានា ដូច្នេះគោលការណ៍ច្បាប់ជាសារវន្ត ដូចជា *គ្មានបទល្មើស ប្រសិនបើគ្មានច្បាប់ចែង*, *ចែងតឹងរ៉ឹង*, *គ្មានទោស ប្រសិនបើគ្មានច្បាប់ចែង*, ដូចមានចែងនៅក្នុងមាត្រា៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា និងភាពចាំបាច់ត្រូវមានសច្ចភាពផ្លូវច្បាប់ទាមទារជាចាំបាច់ឲ្យបញ្ញត្តិជាបទល្មើសព្រហ្ម ទណ្ឌនៅក្នុងច្បាប់ជាតិរបស់កម្ពុជា[83]។ ដូច្នេះ ប្រសិនបើការចែងបញ្ចូលបទល្មើសអន្តរជាតិឲ្យបានច្បាស់គឺជាការចែងច្រំដែលទេនោះ ដូចសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញបានលើកឡើង ដូច្នេះបញ្ហាចោទនឹងលេចឡើងថាតើហេតុអ្វីអ្នកតាក់តែងច្បាប់ចាំបាច់ចែងបញ្ចូលបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាដែលជាហេតុបង្កើតឲ្យមានវិវាទ និងការភាន់ច្រឡំឥតប្រយោជន៍ធ្វើអ្វី។ ទង្វើមិនច្បាស់លាស់

---

[82] សូមមើល ផងដែរ MEAS Bora, International Human Rights Law in Cambodia, *Cambodian Yearbook of Comparative Legal Studies 1 (2010)*, 129-136, at 145, ដែលចង្អុលបង្ហាញគួរឲ្យជឿជាក់ និងផ្តល់ទឡ្ហីករណ៍ថា មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ ពុំអនុញ្ញាតឲ្យយកសន្ធិសញ្ញាមកអនុវត្តដោយផ្ទាល់នោះទេ ដោយ អះអាងថា "ពាក្យពេចន៍ [នៅក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា] 'ទទួលស្គាល់ និងគោរព' [សិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាស ជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ] [...] បង្ហាញយ៉ាងតឹងរ៉ឹងអំពីលក្ខខណ្ឌនៃការធ្វើច្បាប់ ឬ ហាមឃាត់ អាជ្ញាធរមិនឲ្យរំលោភសិទ្ធិនានា។ ការ អនុវត្តដោយផ្ទាល់គឺជាអនុវត្តហួសពីលក្ខខណ្ឌនេះ។ ការអនុវត្តដោយផ្ទាល់ពាក់ព័ន្ធនឹងករណីថាតើចាំបាច់ ឬ ពុំចាំបាច់ត្រូវការច្បាប់ក្នុងការប្រែក្លាយសន្ធិសញ្ញាទៅជាផ្នែកមួយនៃច្បាប់ជាតិ"។

[83] សូមមើលមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលចែងថា "ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬ ការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅបានកើ លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់"។

របស់អ្នកតាក់តែងច្បាប់ដោយចែងបញ្ចូលបទល្មើសអន្តរជាតិ ដែលពុំស្របតាមលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ បានចោទជាបញ្ហាថា តើអ្នកតាក់តែងច្បាប់របស់កម្ពុជាយល់ស្របជាមួយនឹងការយល់យល់ឃើញរបស់ក្រុមប្រឹក្សាធម្មនុញ្ញដែរឬទេ ដោយសារក្រុមប្រឹក្សាធម្មនុញ្ញពុំមែនគ្រាន់តែបង្កើតភាពពុំច្បាស់លាស់ផ្នែកច្បាប់ប៉ុណ្ណោះទេ សំខាន់ជាងនេះទៅទៀត ក្រុមប្រឹក្សាធម្មនុញ្ញបានបង្កើតវិធានវិវាទ ដូចបានលើកឡើងខាងលើ។ ដោយពុំគិតអំពីទស្សនៈរបស់បុគ្គលណាមួយ ឬការបកស្រាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ វាតម្រូវឲ្យអ្នកតាក់តែងច្បាប់ពិនិត្យឡើងវិញលើបញ្ញត្តិច្បាប់ជាតិដែលត្រូវបានដកស្រង់យកមកពីលក្ខន្តិកទីក្រុងរ៉ូម។

## VI. សន្និដ្ឋាន

គោលការណ៍បំពេញបន្ថែមបានផ្តល់កាតព្វកិច្ចឲ្យរដ្ឋយកបទល្មើសនៅក្នុងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ មកចែងបញ្ចូលនៅក្នុងច្បាប់ព្រហ្មទណ្ឌក្នុងស្រុករបស់ខ្លួន។ ប្រទេសកម្ពុជាបានបំពេញកាតព្វកិច្ចនេះរួចហើយដោយចែងបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមនៅក្នុងក្រមព្រហ្មទណ្ឌរបស់ខ្លួន។ ការចែងបទបញ្ញត្តិស្តីពីបទឧក្រិដ្ឋសង្គ្រាមបង្កឲ្យមានបញ្ហា ជាពិសេស ដោយសារបទបញ្ញត្តិនេះងាកយ៉ាងខ្លាំងចេញពីនិយមន័យនៅក្នុងលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយវាក៏ខកខានមិនបានកំណត់អំពើមួយចំនួនជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងយ៉ាងច្បាស់នៅក្នុងលក្ខន្តិកទីក្រុងរ៉ូម។ ភាពខុសគ្នា និងការខកខានក្នុងការអនុម័តបទបញ្ញត្តិមួយចំនួននៅក្នុងលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ អាចនាំឲ្យយើងសន្និដ្ឋានថា តុលាការព្រហ្មទណ្ឌអន្តរជាតិអាចយល់ឃើញថាប្រទេសកម្ពុជាពុំអាចចោទប្រកាន់បទឧក្រិដ្ឋមួយចំនួននៅក្នុងតុលាការក្នុងស្រុករបស់ខ្លួន។ ប្រសិនបើប្រទេសកម្ពុជាមានបំណងចង់រក្សាអធិបតេយ្យពេញលេញនៅក្នុងការចោទប្រកាន់បទឧក្រិដ្ឋអន្តរជាតិ ប្រទេសកម្ពុជាគួរធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌរបស់ខ្លួន។ បើពុំដូច្នោះទេ តុលាការព្រហ្មទណ្ឌអន្តរជាតិ អាចអនុវត្តយុត្តាធិការរបស់គេបាន។